ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១៨ លេខ ១៧ ក្រីមាសទី ០១ ឆ្នាំ ២០១៨

រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារធាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច សារាចរ ប្រកាស

ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១~ព្រះរាជក្រម

១៦-០២-២០១៨ -ព្រះរាជក្រម នស/រកម/០២១៨/០០១ ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្ម ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា ២១៤៥

២~ព្រះរាជក្រឹត្យ

១០-០២-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០២១៨/១៤៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំពោះ ព្រះសង្ឃ ចំនួន ០២ អង្គ ២២១៤

១០-០២-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០២១៨/១៥0 ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម ឧកញ៉ា លោកជំទាវ អស់លោក និងលោកស្រី ចំនួន ២៨ រូប ២២១៥

១០-០២-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០២១៨/១៥១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម និងអស់លោក ចំនួន ៣១ រូប ២២១៦

១០-០២-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០២១៨/១៥២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ កងកម្លាំងប្រដាប់អាវុធ ចំនួន ៨៣ រូប ២២១៨

II~រាជរដ្ឋាភិបាល

អនុក្រឹត្យ

២0-០២-២០១៨ -អនុក្រឹត្យលេខ ២0 អនក្រ.បក ស្តីពី ការប្រើប្រាស់គណនីឯកជនភារូបនីយកម្មសហគ្រាសសាធារណៈរបស់រាជរដ្ឋាភិបាល ២២២៣

២១-០២-២០១៨ -អនុក្រឹត្យលេខ ២១ អនក្រ.បក ស្តីពី បែបបទ និងនីតិវិធីនៃការប្តឹង និងការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម ២២២៥

១៤-០២-២០១៨ -អនុក្រឹត្យលេខ ១៦៥ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ២២៣៤

១៤-០២-២០១៨ -អនុក្រឹត្យលេខ ១៦៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២២៣៦

១៥-០២-២០១៨ -អនុក្រឹត្យលេខ ១៦៧ អនក្រ.តត ស្តីពី ការជូនមេដាយ ២២៤៥

១៥-0២-២0១៨	-អនុក្រឹត្យលេខ ១៦៨ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា	២២៤៨
១៥-0២-២0១៨	-អនុក្រឹត្យលេខ ១៦៩ អនក្រ.តត ស្តីពី ការបញ្ចប់មុខតំណែង និងតែងតាំងមន្ត្រីរាជការ	២២៤៩
១៥-0២-២0១៨	-អនុក្រឹត្យលេខ ១៧0 អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា	២២៥១
១៥-0២-២0១៨	-អនុក្រឹត្យលេខ ១៧១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ	២២៥២
១៥-0២-២0១៨	-អនុក្រឹត្យលេខ ១៧២ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ	២២៥៥
១៩-0២-២0១៨	-អនុក្រឹត្យលេខ ១៧៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ	២២៥៦
១៩-0២-២0១៨	-អនុក្រឹត្យលេខ ១៧៤ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ	២២៥៧

III-ការងារបណ្តាក្រសួង

១-ធនាគារជាតិ នៃ កម្ពុជា

១៦-១0-២0១៧	-សេចក្តីសម្រេចលេខ ធ១២ 0១៧ ២២៤ សសរ ស្តីពី ការបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម	២២៥៩

២-ទីស្តីការរដ្ឋមន្ត្រីក្រសួងការពារជាតិ

0៨-១១-២0១៧	-សេចក្តីសម្រេចលេខ 0៤៦/២0១៧ សសរ ស្តីពី ការបង្កើតគណៈកម្មការរៀបចំសិក្ខាសាលាការងារបច្ចេកទេសទូទាំងកងយោធពលខេមរភូមិន្ទ	២២៦៣

ព្រះរាជក្រម

នស/រកម/០២១៨/០០១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាវជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្ម ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា

មាត្រា១ .-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា ដែលបានចុះហត្ថលេខា នៅរដ្ឋធានីណៃពិដោ នៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា នាថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា២ .-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

មាត្រា៣ .-

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ថ្ងៃ សុក្រ ៤ កើត ខែ ផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៨

ធារ.ស. ១៨០៤. ១៥៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆកររ
នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមទ្បាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ហត្ថលេខា
ប៉ាន សូរស័ក្តិ

លេខ: ១៩៧ ស.ណ
សំណើរដែលមានតម្លៃជាការចែកផ្សាយ
ថ្ងៃអង្គារ ៦ កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧៤...ស/ប៧

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៣

សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រាជរដ្ឋាភិបាល

ប្រទានសិទ្ធិជូនឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានសម្រាប់កម្ពុជា ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀង រវាងរដ្ឋាភិបាលនៃរដ្ឋជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌា ស្តីពីពាណិជ្ជកម្មសេវា ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ។

ក្នុងករណីដែលឯកឧត្តម **ស៊ុន ចាន់ថុល** មានធុរៈជាយថាហេតុ ឯកឧត្តមអាចផ្ទេរសិទ្ធិនេះបាន។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញតាមអំណាចច្បាប់ បានចុះហត្ថលេខាខាងក្រោមលើសិទ្ធិប្រទាននេះ។

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia

រាជរដ្ឋាភិបាល
Royal Government

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

ន: 68.D.F.P

Phnom Penh, October 28 2013

DELEGATION OF FULL POWERS

- Considering the Constitution of the Kingdom of Cambodia,
- Considering the Royal Decree NS/RKT/0913/903 dated 24 September 2013 on the Nomination of the Royal Government of Cambodia,
- Considering the Royal Kram 02/NS/94 dated 20 July 1994 promulgating the Law on the Organization and Functioning of the Council of Ministers,
- Considering the Royal Kram NS/RKM/0196/16 dated 24 January 1996 promulgating the Law on the Establishment of the Ministry of Commerce,
- Pursuant to the Proposal of the Minister of Commerce,

THE ROYAL GOVERNMENT

Delegates herewith Full Powers to **H.E. SUN Chanthol**, Senior Minister, Minister of Commerce, and ASEAN Economic Minister, to sign an Agreement between the Governments of the Association of Southeast Asian Nations (ASEAN) and the Republic of India on Trade in Services under the Framework Agreement on Comprehensive Economic Cooperation.

In case **H.E. SUN Chanthol** is not available, he can delegate this Full Powers.

In witness whereof, the undersigned, the Prime Minister of the Kingdom of Cambodia, with Full Powers duly entrusted to him, has signed the Delegation of Full Powers.

Prime Minister

Samdech Akka Moha Sena Padei Techo HUN SEN

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្ម ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ រវាង សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា

បុព្វកថា

រដ្ឋាភិបាលនៃប្រទេសព្រុយណេដារូសាឡឹម (ព្រុយណេដារូសាឡឹម) ព្រះរាជាណាចក្រកម្ពុជា (កម្ពុជា) សាធារណរដ្ឋឥណ្ឌូនេស៊ី(ឥណ្ឌូនេស៊ី)សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ(ឡាវ) ម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា (មីយ៉ានម៉ា) សាធារណរដ្ឋហ្វីលីពីន (ហ្វីលីពីន) សាធារណរដ្ឋសឹង្ហបុរី (សឹង្ហបុរី) ព្រះរាជាណាចក្រថៃ (ថៃ) និងសាធារណរដ្ឋសង្គមនិយមវៀតណាម (វៀតណាម)ជាប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ហៅជារួមថា "អាស៊ាន" ឬ "បណ្តាប្រទេសសមាជិកអាស៊ាន" ឬ ដោយឡែកថា "ប្រទេសសមាជិកអាស៊ាន") និងសាធារណរដ្ឋឥណ្ឌា (ឥណ្ឌា) ។

ដោយរំលឹកឡើងវិញ នូវកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា (កិច្ចព្រមព្រៀងក្របខ័ណ្ឌ) ដែលបានចុះហត្ថលេខាដោយប្រមុខរដ្ឋ/រដ្ឋាភិបាល នៃបណ្តាប្រទេសសមាជិកអាស៊ាន និងសាធារណរដ្ឋឥណ្ឌា នៅទីក្រុងបាលី ប្រទេសឥណ្ឌូនេស៊ី នាថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៣ និងពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា ដែលបានចុះហត្ថលេខានៅទីក្រុងបាងកក ប្រទេសថៃ នាថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៩ ។

ដោយរំលឹកឡើងវិញ មាត្រា៤ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ដែលអំពាវនាវឲ្យអាស៊ាន និង ឥណ្ឌា ធ្វើសេរីភាវូបនីយកម្មបន្តបន្ទាប់ និងលុបបំបាត់នូវការរើសអើងទាំងឡាយ និង/ឬ ហាមឃាត់វិធានការដែលមានការរើសអើងថ្មីៗបន្ថែមទៀត ចំពោះពាណិជ្ជកម្មសេវាកម្មរវាងបណ្តាភាគី និងដើម្បីពង្រីកជម្រៅ និងវិសាលភាពពាណិជ្ជកម្មសេវាកម្ម ដែលមានវិសាលភាពគ្របដណ្តប់ធំជាងការសន្យារបស់បណ្តាភាគី ក្រោមកិច្ចព្រមព្រៀងទូទៅ ស្តីពីពាណិជ្ជកម្មសេវាកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO)។

ដោយខិតខំប្រឹងប្រែង លើកកម្ពស់កិច្ចសហប្រតិបត្តិការលើវិស័យសេវាកម្មរវាងបណ្តាភាគីដើម្បីកែលម្អប្រសិទ្ធភាព និងការប្រកួតប្រជែង ក៏ដូចជាធ្វើពិពិធកម្មការផ្គត់ផ្គង់ និងការចែកចាយសេវាកម្ម របស់អ្នកផ្គត់ផ្គង់សេវាកម្មនីមួយៗនៃភាគីពាក់ព័ន្ធលើការអនុវត្ត ស្របតាមរយៈពេលកំណត់ដែលបានឯកភាពគ្នាទៅវិញទៅមករបស់បណ្តាភាគី នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ។

ដោយរំលឹកឡើងវិញ នូវសេចក្តីណែនាំពីកិច្ចពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-ឥណ្ឌា នៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០០៨ នៅប្រទេសសឹង្ហបុរី ឲ្យមន្ត្រីពាក់ព័ន្ធចាប់ផ្តើមការចរចាជាផ្លូវការ ឲ្យបានឆាប់លើពាណិជ្ជកម្មសេវាកម្ម និងវិនិយោគ ក្នុងពេលតែមួយ និងឈានទៅបញ្ចប់ការចរចាកិច្ចព្រមព្រៀងទាំងពីរនេះនៅ

ក្នុងឆ្នាំ២០០៩ ដើម្បីសម្រេចបាននូវកិច្ចព្រមព្រៀងស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយអាស៊ាន-ឥណ្ឌា ពេញលេញមួយ ។

ដោយអះអាងឡើងវិញ មាត្រា២ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន-ឥណ្ឌា មានបទប្បញ្ញត្តិមួយចំនួនចែងអំពីប្រព្រឹត្តិកម្មពិសេស និងប្រព្រឹត្តិកម្មដោយឡែកសម្រាប់ប្រទេសកម្ពុជា ប្រទេសឡាវ ប្រទេសមីយ៉ាន់ម៉ា និងប្រទេសវៀតណាម និងផ្តល់ភាពទន់ភ្លន់ចំពោះបណ្តាភាគីលើវិស័យដែលមានលក្ខណៈរសើបរបស់ខ្លួន ដោយភាពទន់ភ្លន់ទាំងនេះនឹងត្រូវចរចា និងឯកភាព ផ្អែកលើគោលការណ៍ផលប្រយោជន៍ទៅវិញទៅមក។

ដោយទទួលស្គាល់ នូវសិទ្ធិរបស់ភាគីទាំងអស់ក្នុងការត្រួតពិនិត្យ និងចេញបទប្បញ្ញត្តិថ្មីៗលើការផ្តត់ផ្តង់សេវាកម្មនៅក្នុងដែនដីរបស់ខ្លួន ស្របតាមទិសដៅគោលនយោបាយជាតិ ដោយសារមានភាពមិនស៊ីមេទ្រីគ្នាលើកម្រិតនៃការអភិវឌ្ឍបទប្បញ្ញត្តិសេវាកម្មរបស់ភាគីទាំងអស់ និងស្របតាមតម្រូវការចាំបាច់របស់ភាគីទាំងអស់ក្នុងការប្រើប្រាស់សិទ្ធិនេះ ។

បានព្រមព្រៀងដូចខាងក្រោម៖

ផ្នែកទី១ ៖ វិសាលភាព និងនិយមន័យ

មាត្រា ១
វិសាលភាព

១. កិច្ចព្រមព្រៀងនេះអនុវត្តចំពោះរាល់វិធានការទាំងឡាយ ដោយភាគីពាក់ព័ន្ធនឹងពាណិជ្ជកម្មសេវាកម្ម។

២. កិច្ចព្រមព្រៀងនេះមិនត្រូវបានអនុវត្តចំពោះ៖

(ក) សេវាកម្មដែលត្រូវបានផ្តត់ផ្តង់ក្រោមការអនុវត្តរបស់អាជ្ញាធររដ្ឋាភិបាល ក្នុងដែនដីរបស់ភាគីនីមួយៗ

(ខ) ច្បាប់ បទប្បញ្ញត្តិ ឬតម្រូវការនានានៅក្នុងការធ្វើលទ្ធកម្ម ដែលធ្វើឡើងដោយភ្នាក់ងាររដ្ឋាភិបាលចំពោះសេវាកម្មដែលបានទិញសម្រាប់រដ្ឋាភិបាល ដោយមិនមានគោលដៅលក់ឡើងវិញ ឬប្រើប្រាស់ក្នុងការផ្តត់ផ្តង់សេវាកម្ម សម្រាប់លក់ជាលក្ខណៈអាជីវកម្ម និង

(គ) ច្បាប់នាវាចរណ៍ នៅក្នុងសេវាកម្មដឹកជញ្ជូនផ្លូវសមុទ្រ ។

មាត្រា ២
និយមន័យ

សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ៖

(ក) **សេវាកម្មដែលត្រូវបានផ្តត់ផ្តង់ក្រោមការអនុវត្តរបស់អាជ្ញាធររដ្ឋាភិបាល** មានន័យថា រាល់សេវាកម្មទាំងឡាយ ដែលត្រូវបានផ្តត់ផ្តង់ក្នុងរូបភាពមិនមែនជាការធ្វើពាណិជ្ជកម្ម ឬ ប្រកួតប្រជែងជាមួយអ្នកផ្តត់ផ្តង់សេវាកម្មមួយ ឬច្រើនផ្សេងទៀត។

(ខ) **វត្តមានពាណិជ្ជកម្ម** មានន័យថា ជាប្រភេទធុរកិច្ច ឬ ការបង្កើតជាលក្ខណៈអាជីពទាំងឡាយណា ដែលរួមបញ្ចូល៖

១. ការបង្កើត ការកាន់កាប់ ឬ ការជួសជុល ពីនីតិបុគ្គល ឬ

២. ការបង្កើត ឬ ការជួសជុលសាខា ឬ ការិយាល័យតំណាង នៅក្នុងដែនដីរបស់ភាគីមួយ ក្នុងគោលបំណងផ្តត់ផ្តង់សេវាកម្មមួយ ។

(គ) **ពន្ធផ្ទាល់** រួមបញ្ចូលនូវបណ្តាពន្ធលើប្រាក់ចំណូលសរុប មូលធនសរុប ឬ លើសមាសធាតុនៃប្រាក់ចំណូល ឬ នៃមូលធន រួមមានពន្ធលើចំណូលពីការផ្ទេរកម្មសិទ្ធិ ពន្ធលើអចលនទ្រព្យ កេរ្តិ៍មរតក និងអំណោយ និងពន្ធលើប្រាក់ឈ្នួល ឬ ប្រាក់បៀវត្សន៍សរុប ដែលចំណាយដោយសហគ្រាស ក៏ដូចជាពន្ធលើការរំលោះមូលធន។

(ឃ) **GATS មានន័យថា** កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម។

(ង) **នីតិបុគ្គល** មានន័យថានីតិបុគ្គលទាំងឡាយណាដែលត្រូវបានបង្កើតឡើងដោយស្របច្បាប់ ឬ ស្ថិតក្រោមច្បាប់ជាធរមាន ទោះជាត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីប្រាក់ចំណេញ ឬ ក្នុងគោលបំណងដទៃទៀត ទោះជាកម្មសិទ្ធិឯកជន ឬ របស់រដ្ឋាភិបាលក្តី រួមមាន សាជីវកម្ម ក្រុមហ៊ុនផ្តាច់មុខ ក្រុមហ៊ុនដៃគូ ក្រុមហ៊ុនចំរុះទុន សហគ្រាសឯកកម្មសិទ្ធិ ឬ សមាគម។

(ច) **នីតិបុគ្គលនៃភាគីមួយផ្សេងទៀត** មានន័យថា នីតិបុគ្គលដែល ៖

i. ត្រូវបានបង្កើត ឬ រៀបចំឡើងនៅក្រោមច្បាប់របស់ភាគីផ្សេងទៀត និងចូលរួមក្នុងប្រតិបត្តិការធុរកិច្ចជាដុំកំភួន នៅក្នុងដែនដីរបស់ភាគីនោះ ឬ ភាគីដទៃទៀត ឬ

ii. ក្នុងករណីការផ្តត់ផ្តង់សេវាកម្មត្រូវបានធ្វើឡើងតាមរយៈវត្តមានពាណិជ្ជកម្ម ដែលត្រូវបានកាន់កាប់ ឬ គ្រប់គ្រងដោយ៖

(កក) រូបវន្តបុគ្គលនៃភាគីនោះឬ

(ខខ) នីតិបុគ្គលនៃភាគីដទៃទៀតដែលមានចែងក្នុងកថាខណ្ឌរង(i) ។

(ឆ) **នីតិបុគ្គល ៖**

i. ត្រូវបានកាន់កាប់ដោយបុគ្គលទាំងឡាយនៃភាគីមួយ ប្រសិនបើជាង៥០ភាគរយនៃទុនរបស់ក្រុមហ៊ុន ត្រូវបានកាន់កាប់ដោយបុគ្គលទាំងឡាយនៃភាគីនោះ

ii. ត្រូវបានគ្រប់គ្រងដោយបុគ្គលទាំងឡាយនៃភាគីមួយ ប្រសិនបើបុគ្គលទាំងឡាយនោះមានអំណាចតែងតាំងសមាសភាពភាគច្រើននៃនាយករបស់ខ្លួន ឬ មានសិទ្ធិតាមផ្លូវច្បាប់ក្នុងការដឹកនាំសកម្មភាពក្រុមហ៊ុននោះ

iii. ចងសម្ព័ន្ធ ជាមួយបុគ្គលណាមួយផ្សេងទៀត នៅពេលដែលនីតិបុគ្គលនោះគ្រប់គ្រង ឬ ត្រូវបានគ្រប់គ្រងដោយបុគ្គលណាមួយផ្សេងទៀត ឬ នៅពេលដែលនីតិបុគ្គល និងបុគ្គលផ្សេងទៀតនោះ ត្រូវបានគ្រប់គ្រងដោយបុគ្គលតែមួយដូចគ្នា។

(ជ) **នីតិវិធីនៃការចេញអាជ្ញាប័ណ្ណ** មានន័យថា វិធានរដ្ឋបាល ឬ វិធានជានីតិវិធី ដែលរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលស្នើសុំសិទ្ធិក្នុងការផ្តត់ផ្តង់សេវាកម្ម រួមបញ្ចូលទាំងការកែប្រែ ឬការបន្តអាជ្ញាប័ណ្ណ ចាំបាច់ត្រូវបង្ហាញដើម្បីអោយស្របជាមួយលក្ខខណ្ឌតម្រូវរបស់អាជ្ញាប័ណ្ណ។

(ឈ) **លក្ខខណ្ឌតម្រូវរបស់អាជ្ញាប័ណ្ណ** មានន័យថា លក្ខខណ្ឌចាំបាច់សំខាន់ៗ ក្រៅពីលក្ខខណ្ឌគុណវុឌ្ឍិ ដែលរូបវន្តបុគ្គល ឬនីតិបុគ្គលមួយត្រូវអនុវត្តតាម ដើម្បីទទួលបាន កែតម្រូវ ឬ បន្តសិទ្ធិអនុញ្ញាតសម្រាប់ផ្តត់ផ្តង់សេវាកម្ម។

(ញ) **វិធានការ** មានន័យថា វិធានការទាំងណា ដែលធ្វើឡើងដោយភាគីមួយ ទោះជាក្នុងទម្រង់ច្បាប់ បទប្បញ្ញត្តិ វិធាន នីតិវិធី សេចក្តីសម្រេច វិធានការរដ្ឋបាល ឬ ក្នុងទម្រង់ផ្សេងៗទៀត។

(ដ) **វិធានការដោយភាគី** មានន័យថា ជាវិធានការទាំងឡាយណា ដែលធ្វើឡើងដោយ៖

i. រដ្ឋាភិបាលថ្នាក់កណ្តាល តំបន់ ឬ មូលដ្ឋាន និង

ii. អង្គការក្រៅរដ្ឋាភិបាល ដែលទទួលបានអំណាចប្រទានពីរដ្ឋាភិបាល ឬ អាជ្ញាធរថ្នាក់កណ្តាល តំបន់ ឬ មូលដ្ឋាន ។

ដើម្បីបំពេញតាមកាតព្វកិច្ច និងការសន្យារបស់ខ្លួនក្រោមកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗត្រូវចាត់វិធានការសមស្រប ដើម្បីធានាលើការប្រតិបត្តិរបស់ខ្លួន តាមរយៈរដ្ឋាភិបាលថ្នាក់តំបន់ និងមូលដ្ឋាន អាជ្ញាធរ និងអង្គការក្រៅរដ្ឋាភិបាលនានា នៅក្នុងដែនដីរបស់ខ្លួន ។

(ឋ) **វិធានការនានាដោយភាគីដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម** រួមបញ្ចូលនូវវិធានការនានាដែលធ្វើឡើងចំពោះ៖

i. ការទិញ ការទូទាត់ ឬ ការប្រើប្រាស់សេវាកម្ម

ii. ការទទួលបាន និងការប្រើប្រាស់សេវាកម្ម ដែលតម្រូវដោយភាគី សម្រាប់ផ្តត់ផ្តង់ជាសាធារណៈ

iii. វត្តមានរបស់បុគ្គលមកពីភាគីណាមួយ ក្នុងការផ្តត់ផ្តង់សេវាកម្មនៅក្នុងទឹកដីរបស់ភាគីណាមួយទៀត រួមបញ្ចូលទាំងវត្តមានពាណិជ្ជកម្ម។

(ឌ) **អ្នកផ្តត់ផ្តង់សេវាកម្មផ្តាច់មុខ** មានន័យថា ជាបុគ្គលសាធារណៈ ឬ ឯកជន នៅក្នុងទីផ្សារពាក់ព័ន្ធនៅក្នុងដែនដីរបស់ភាគីមួយ ដែលត្រូវបានផ្តល់សិទ្ធិអនុញ្ញាត ឬ បង្កើតឡើងជាផ្លូវការ ឬ មានសុពលភាព ពីភាគីនោះជាអ្នកផ្តត់ផ្តង់ផ្តាច់មុខនូវសេវាកម្មនោះ ។

(ឍ) **រូបវន្តបុគ្គលរបស់ភាគីមួយទៀត** មានន័យថា រូបវន្តបុគ្គលដែលស្នាក់អាស្រ័យនៅក្នុងដែនដីរបស់ភាគីណាមួយនោះ ឬនៅកន្លែងផ្សេងទៀត និង ដែលក្រោមផ្លូវច្បាប់របស់ភាគីនោះ៖

i. គឺជាជនជាតិរបស់ភាគីនោះ ឬ

ii. មានសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍[១] ក្នុងដែនដីរបស់ភាគីមួយទៀតនោះ ក្នុងករណីភាគីមួយនោះផ្តល់ប្រព្រឹត្តិកម្មចំពោះអ្នកស្នាក់នៅអចិន្ត្រៃយ៍ដូចគ្នាទាំងស្រុងនឹងប្រព្រឹត្តិកម្ម ដែល

---

[១] ក្នុងករណីប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ឡាវ មីយ៉ាន់ម៉ា ថៃ វៀតណាម និងឥណ្ឌា រូបវន្តបុគ្គលរបស់ភាគីមួយ ត្រូវបានកម្រិតត្រឹមរូបវន្តបុគ្គលណាមួយដែលស្នាក់នៅក្នុងដែនដីភាគីមួយទៀត ឬកន្លែងណាផ្សេង ហើយដែលក្រោមច្បាប់របស់ភាគីមួយនោះ គឺជារូបវន្តបុគ្គលរបស់ភាគីនោះ។ ដូចនេះ ស្របតាមគោលការណ៍បដិការ កិច្ចព្រមព្រៀងនេះមិនត្រូវអនុវត្តចំពោះនិវេសនជនអចិន្ត្រៃយ៍របស់ប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ឡាវ មីយ៉ាន់ម៉ា ថៃ វៀតណាម និងឥណ្ឌាឡើយ។ នៅពេលភាគីណាមួយក្នុងចំណោមភាគីទាំងនេះអនុម័តច្បាប់ក្នុងស្រុក ស្តីពីប្រព្រឹត្តិកម្មនិវេសនជនអចិន្ត្រៃយ៍នៃភាគីមួយផ្សេងទៀតក្នុងកិច្ចព្រមព្រៀង ឬក្រៅកិច្ចព្រមព្រៀង ត្រូវមានកិច្ចចរចាលើបញ្ហាពាក់ព័ន្ធថាតើ គួរបញ្ចូលនិវេសនជនអចិន្ត្រៃយ៍ ទៅក្នុងដែនកំណត់នៃរូបវន្តបុគ្គល ក្រោមកិច្ចព្រមព្រៀងនេះ ស្របតាមភាគីនោះដែរទេ ។

ផ្តល់ចំពោះជាតិសាសន៍ខ្លួន ពាក់ព័ន្ធនឹងវិធានការដែលជះឥទ្ធិពលលើពាណិជ្ជកម្មសេវាកម្ម ដូចដែលបានជូនដំណឹងបន្ទាប់ពីការចូលជាធរមានរបស់កិច្ចព្រមព្រៀងនេះ ដែលក្នុងនោះ គ្មានភាគីណាមួយត្រូវជាប់កាតព្វកិច្ចផ្តល់ឲ្យអ្នកស្នាក់នៅអចិន្ត្រៃយ៍នូវប្រព្រឹត្តិកម្មក្នុងលក្ខខណ្ឌល្អជាង ដែលត្រូវផ្តល់ដោយភាគីជាទៃចំពោះអ្នកស្នាក់នៅអចិន្ត្រៃយ៍ទាំងនោះឡើយ។ សេចក្តីជូនដំណឹងនេះ ត្រូវរួមបញ្ចូលនូវការធានានូវទំនួលខុសត្រូវដូចគ្នា ដែលភាគីផ្សេងទៀតមានចំពោះជនជាតិរបស់ខ្លួន ស្តីពីអ្នករស់នៅអចិន្ត្រៃយ៍ ស្របតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន ។

(ណ) **បណ្តាភាគី** សំដៅលើបណ្តាប្រទេសសមាជិកអាស៊ាន និងសាធារណរដ្ឋឥណ្ឌា ជារួម។

(ត) **ភាគី** សំដៅលើប្រទេសសមាជិកអាស៊ានណាមួយ ឬ សាធារណរដ្ឋឥណ្ឌា។

(ថ) **បុគ្គល** សំដៅលើរូបវន្តបុគ្គល ឬ នីតិបុគ្គល។

(ទ) **នីតិវិធីគុណវុឌ្ឍិ** មានន័យថា វិធាននីតិវិធី ឬ បែបបទរដ្ឋបាល ដែលរូបវន្តបុគ្គលត្រូវប្រកាន់ខ្ជាប់ស្របតាមតម្រូវការគុណវុឌ្ឍិ ក្នុងគោលបំណងទទួលបានសិទ្ធិអនុញ្ញាតផ្តត់ផ្តង់សេវាកម្ម ។

(ធ) **តម្រូវការគុណវុឌ្ឍិ** មានន័យថា តម្រូវការសំខាន់ៗពាក់ព័ន្ធនឹងសមត្ថភាពរបស់រូបវន្តបុគ្គលក្នុងការផ្តត់ផ្តង់សេវាកម្ម ហើយដែលតម្រូវឲ្យមាន ក្នុងគោលបំណងទទួលបានសិទ្ធិអនុញ្ញាតផ្តត់ផ្តង់សេវាកម្ម ។

(ន) **វិស័យ** នៃសេវាកម្ម មានន័យថា៖

i. សំដៅលើការសន្យាជាក់លាក់ មួយ ឬ ច្រើន ឬ ទាំងអស់នៃអនុវិស័យរបស់សេវាកម្មនោះ ដូចដែលបានបញ្ជាក់នៅក្នុងរយៈពេលសន្យារបស់ភាគីមួយ

ii. វិស័យសេវាកម្មទាំងមូល រួមទាំងអនុវិស័យសេវាកម្មទាំងអស់។

(ប) **បណ្តាសេវាកម្ម** រួមបញ្ចូលសេវាកម្ម នៅក្នុងវិស័យនានា លើកលែងតែសេវាកម្មដែលត្រូវបានផ្តត់ផ្តង់ដោយអាជ្ញាធររដ្ឋាភិបាល ។

(ផ) **អ្នកប្រើប្រាស់សេវាកម្ម** មានន័យថា បុគ្គលទាំងឡាយណាដែលទទួល ឬ ប្រើប្រាស់សេវាកម្ម។

(ព) **សេវាកម្មរបស់ភាគីណាមួយផ្សេងទៀត** មានន័យថា សេវាកម្មមួយដែលត្រូវបានផ្តត់ផ្តង់៖

i. ពី ឬ នៅក្នុងដែនដីរបស់ភាគីណាមួយនោះ ឬ នៅក្នុងករណីដឹកជញ្ជូនផ្លូវសមុទ្រ ដោយនាវាដែលបានចុះបញ្ជីក្រោមច្បាប់ ឬ ដោយបុគ្គលណាមួយរបស់ភាគីណាមួយនោះ ដែលផ្តត់ផ្តង់សេវាកម្ម តាមរយៈប្រតិបត្តិការរបស់នាវានោះ និង/ឬ ការប្រើប្រាស់ទាំងស្រុង ឬ ជាផ្នែក ឬ

ii. ក្នុងករណីការផ្តត់ផ្តង់សេវាកម្មតាមរយៈវត្តមានពាណិជ្ជកម្ម ឬ តាមរយៈវត្តមានរបស់រូបវន្តបុគ្គល ដោយអ្នកផ្តត់ផ្តង់សេវាកម្មរបស់ភាគីណាមួយនោះ ។

(ភ) **អ្នកផ្តត់ផ្តង់សេវា** មានន័យថា បុគ្គលទាំងឡាយណា ដែលធ្វើការផ្តត់ផ្តង់សេវាកម្ម[២] ។

---

[២] ក្នុងករណីសេវាកម្មពុំត្រូវបានផ្តត់ផ្តង់ផ្ទាល់ដោយនីតិបុគ្គលណាមួយ ប៉ុន្តែតាមរយៈទម្រង់ផ្សេងៗនៃវត្តមានតំណាងពាណិជ្ជកម្ម ដូចជា សាខាណាមួយ ការិយាល័យតំណាងណាមួយ នោះអ្នកផ្តត់ផ្តង់សេវាកម្ម (ឧ. នីតិបុគ្គល) ត្រូវទទួលបានប្រព្រឹត្តិកម្មដែលផ្តល់សម្រាប់បណ្តាអ្នកផ្តត់ផ្តង់សេវាកម្មនៅ

(ម) **ការផ្តត់ផ្តង់សេវាកម្ម** រួមបញ្ចូលនូវផលិតកម្ម ការចែកចាយ ការធ្វើទីផ្សារ ការលក់ និងការដឹកជញ្ជូនសេវាកម្ម។

(យ) **ស្តង់ដារបច្ចេកទេស** មានន័យថា វិធានការទាំងឡាយណាដែលកំណត់នូវលក្ខណៈបច្ចេកទេសរបស់សេវាកម្ម ឬ បែបផែនដែលសេវាកម្មត្រូវបានផ្តត់ផ្តង់ ។ ស្តង់ដារបច្ចេកទេសក៏រួមបញ្ចូលផងដែរនូវនីតិវិធីពាក់ព័ន្ធនឹងការដាក់ឲ្យអនុវត្តនូវស្តង់ដារនោះ ។

(រ) **ពាណិជ្ជកម្មសេវាកម្ម** គឺជាការផ្តត់ផ្តង់សេវាកម្ម៖

i. ពីដែនដីរបស់ភាគីមួយ ចូលក្នុងដែនដីរបស់ភាគីមួយផ្សេងទៀត (" ឆ្លងកាត់ព្រំដែន")

ii. នៅក្នុងដែនដីរបស់ភាគីមួយ ទៅឲ្យអ្នកប្រើប្រាស់សេវាកម្ម នៅក្នុងដែនដីរបស់ភាគីមួយទៀត ("ការប្រើប្រាស់នៅបរទេស")

iii. ដោយអ្នកផ្តត់ផ្តង់សេវាកម្មរបស់ភាគីមួយ តាមរយៈវត្តមានពាណិជ្ជកម្ម នៅក្នុងដែនដីរបស់ភាគីណាមួយទៀត ("វត្តមានពាណិជ្ជកម្ម")

iv. ដោយអ្នកផ្តត់ផ្តង់សេវាកម្មរបស់ភាគីមួយ តាមរយៈវត្តមានរូបវន្តបុគ្គលរបស់ភាគីណាមួយនៅ ក្នុងដែនដីរបស់ភាគីណាមួយផ្សេងទៀត ("វត្តមានរបស់រូបវន្តបុគ្គល") ។

ផ្នែកទី ២ ៖ កាតព្វកិច្ច និងវិន័យ

មាត្រា ៣

តម្លាភាព

១. លើកលែងក្នុងករណីស្ថានភាពបន្ទាន់ និងយ៉ាងយូរបំផុតត្រឹមការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗត្រូវបោះពុម្ពផ្សាយនូវវិធានការពាក់ព័ន្ធនៃការអនុវត្តទូទៅដែលជាប់ទាក់ទង ឬ ប៉ះពាល់ដល់ការអនុវត្តកិច្ចព្រមព្រៀងនេះ ។ កិច្ចព្រមព្រៀងអន្តរជាតិនានាដែលជាប់ទាក់ទង ឬ ប៉ះពាល់ដល់ពាណិជ្ជកម្មសេវាកម្មដែលភាគីមួយជាហត្ថលេខី ក៏ត្រូវបានបោះពុម្ពផ្សាយផងដែរ ។

២. ក្នុងករណីដែលការបោះពុម្ពផ្សាយដូចបានលើកឡើងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ មិនអាចអនុវត្តបានព័ត៌មាននោះត្រូវតែផ្សព្វផ្សាយជាសាធារណៈ ។

៣. ភាគីនីមួយៗត្រូវឆ្លើយតបឲ្យបានទាន់ពេលវេលានូវរាល់សំណើទាំងអស់របស់ភាគីដទៃទៀតលើព័ត៌មានជាក់លាក់ស្តីពី វិធានការនៃការអនុវត្តទូទៅ ឬ កិច្ចព្រមព្រៀងអន្តរជាតិនានា ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ ។ ភាគីនីមួយៗត្រូវបង្កើតការិយាល័យទំនាក់ទំនងមួយ ឬ ច្រើន ដើម្បីផ្តល់ព័ត៌មានជាក់លាក់ទៅឲ្យភាគីផ្សេងទៀតនូវរាល់បញ្ហាទាំងអស់ បន្ទាប់ពីទទួលបានសំណើ ។

មាត្រា ៤

ការឆ្លើយព័ត៌មានសម្ងាត់

ក្រោមកិច្ចព្រមព្រៀងនេះ ។ ប្រព្រឹត្តិកម្មបែបនេះ ត្រូវតែបន្តផ្តល់ជូនវត្តមាន ដែលសេវាកម្មត្រូវបានផ្តត់ផ្តង់ ហើយមិនចាំបាច់បន្តផ្តល់ជូនផ្នែកផ្សេងទៀតរបស់អ្នកផ្តត់ផ្តង់ដែលមានទីតាំងក្រៅដែនដីដែលសេវាកម្មត្រូវបានផ្តត់ផ្តង់។

មាត្រា៣ស្តួន នៃកិច្ចព្រមព្រៀងទូទៅស្តីពីសេវាកម្ម (GATS) ទោះជាមានការកែប្រែក៏ដោយ ត្រូវបានបញ្ចូល និងជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះដែរ ។

មាត្រា ៥
បទប្បញ្ញត្តិក្នុងស្រុក

១. នៅក្នុងចំណុចការសន្យាជាក់លាក់ក្រោមផ្នែកទី៣ នៅក្នុងវិស័យនានានៃកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗត្រូវធានាថា រាល់វិធានការទាំងអស់នៃការអនុវត្តទូទៅដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម ត្រូវធ្វើឡើងក្នុងលក្ខណៈសមស្រប សក្យានុម័ត និងមិនលំអៀង ។

២. (ក) ភាគីនីមួយៗត្រូវរក្សា ឬ បង្កើតឲ្យបានឆាប់តាមដែលអាចធ្វើទៅបាននូវសាលាក្តីយុត្តិធម៌ អាជ្ញាកណ្តាលពាណិជ្ជកម្ម តុលាការរដ្ឋបាល ឬនីតិវិធី តាមសំណើរបស់អ្នកផ្តត់ផ្តង់សេវាកម្មដែលរងការប៉ះពាល់ ដើម្បីឲ្យមានការត្រួតពិនិត្យឡើងវិញភ្លាមៗ ឬ មានដំណោះស្រាយសមរម្យ លើសេចក្តីសម្រេចរដ្ឋបាលនានាដែលប៉ះពាល់ដល់ពាណិជ្ជកម្មសេវាកម្ម។ ក្នុងករណីដែលនីតិវិធីទាំងនោះ មិនស្ថិតក្រោមភ្នាក់ងារទទួលបន្ទុកសេចក្តីសម្រេចរដ្ឋបាលពាក់ព័ន្ធ ភាគីនោះត្រូវធានាថា នីតិវិធីទាំងនោះ ត្រូវបានអនុវត្តដោយសក្យានុម័ត និងមិនលំអៀង ។

(ខ) បទប្បញ្ញត្តិទាំងឡាយនៃកថាខណ្ឌ ២.(ក) នៃមាត្រានេះ នឹងមិនត្រូវបានបកស្រាយ ដើម្បីតម្រូវឲ្យភាគីណាមួយ បង្កើតតុលាការ ឬ នីតិវិធីទាំងឡាយ ដែលផ្ទុយទៅនឹងនឹងរចនាសម្ព័ន្ធរដ្ឋធម្មនុញ្ញ ឬ ប្រព័ន្ធច្បាប់របស់ខ្លួនឡើយ ។ ប៉ុន្តែក្នុងករណីដែលតុលាការ ឬនីតិវិធី មិនអាចរៀបចំធ្វើទៅបាន ភាគីពាក់ព័ន្ធត្រូវធានាថាមានមធ្យោបាយដោះស្រាយសមរម្យសម្រាប់អ្នកផ្តត់ផ្តង់សេវាកម្មដែលរងផលប៉ះពាល់ដូចបានលើកឡើងក្នុងកថាខណ្ឌ ២.(ក) នៃមាត្រានេះ តាមរយៈនីតិវិធីច្បាប់ធម្មតា ឬនីតិវិធីច្បាប់ឧបគតិយុត្តិ របស់ភាគីនោះ[៣] ។

៣. នៅពេលដែលការផ្តត់ផ្តង់សេវាកម្ម លើការសន្យាជាក់លាក់ណាមួយក្រោមកិច្ចព្រមព្រៀងនេះ តម្រូវឲ្យមានការសុំសិទ្ធិអនុញ្ញាត អាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីនីមួយៗត្រូវ៖

(ក) ជូនដំណឹងដល់អ្នកដាក់ពាក្យស្នើសុំអំពីការសម្រេច នៅក្នុងរយៈពេលសមស្របណាមួយ បន្ទាប់ពីការពាក្យសុំត្រូវបានពិនិត្យចប់សព្វគ្រប់ តាមច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុក។

(ខ) ផ្តល់ព័ត៌មានឲ្យបានទាន់ពេលវេលាតាមសំណើរបស់អ្នកស្នើសុំ អំពីស្ថានភាពនៃពាក្យស្នើសុំ រួមទាំងពាក្យស្នើសុំដែលមិនបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់។ ចំពោះករណីពាក្យស្នើសុំដែលមិនបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ អាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីនីមួយៗត្រូវបញ្ជាក់ពីព័ត៌មានបន្ថែមដើម្បីបំពេញចំណុចខ្វះខាតទាំងនោះ និងផ្តល់ឱកាសដល់អ្នកដាក់ពាក្យស្នើសុំ ធ្វើការកែសម្រួល ឬបំពេញបន្ថែម ក្នុងអំឡុងពេលសមស្របមួយ។

(គ) ប្រសិនបើពាក្យស្នើសុំត្រូវបានបដិសេធ ឬលុបចោល ត្រូវជូនដំណឹងតាមលទ្ធភាពតាមដែលអាចធ្វើទៅបានដោយគ្មានការពន្យាពេល ដល់អ្នកដាក់ពាក្យសុំស្នើជាលាយលក្ខអក្សរ ដោយបញ្ជាក់ពី

---

[៣] ដើម្បីឲ្យកាន់តែច្បាស់ ការអនុវត្តកថាខណ្ឌនេះ ត្រូវគ្រប់គ្រងដោយច្បាប់ និងបទប្បញ្ញត្តិ របស់បណ្តាភាគីរៀងខ្លួន ។

មូលហេតុច្បាស់លាស់។ អ្នកដាក់ពាក្យស្នើអាចដាក់សំណើសាជាថ្មីឡើងវិញ ទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន ។

៤. ដើម្បីឲ្យប្រាកដថា វិធានការនានាពាក់ព័ន្ធនឹងតម្រូវការគុណវុឌ្ឍិ និងនីតិវិធី បទដ្ឋានបច្ចេកទេស និងលក្ខខណ្ឌចាំបាច់សម្រាប់ផ្តល់អាជ្ញាប័ណ្ណ នឹងមិនបង្កើតជារបាំងដល់ការធ្វើពាណិជ្ជកម្មសេវាកម្ម ភាគីទាំងអស់ត្រូវពិនិត្យឡើងវិញរួមគ្នាលើលទ្ធផលនៃការចរចាអំពីវិន័យផ្ទៃក្នុងនៃវិធានការទាំងនោះ ដោយអនុលោមតាមកថាខណ្ឌទី៤ របស់មាត្រា ៤ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម (GATS) ដើម្បីដាក់បញ្ចូលទៅក្នុងកិច្ចព្រមព្រៀងនេះ។ ភាគីទាំងអស់កត់សម្គាល់ថា វិន័យទាំងអស់នោះមានគោលបំណងដើម្បីធានាដល់លក្ខខណ្ឌ ក្នុងចំណោមនោះ រួមមាន ៖

(ក) ផ្អែកលើលក្ខណៈវិនិច្ឆ័យនៃកម្មវត្ថុ និងតម្លាភាព ដូចជា សមត្ថភាព និងលទ្ធភាពក្នុងការផ្គត់ផ្គង់សេវាកម្ម។

(ខ) មិនមែនជាបន្ទុកបន្ថែម ដល់ការធានាគុណភាពនៃសេវាកម្ម។

(គ) មិនមែនជាការរឹតបន្តឹងដល់ការផ្គត់ផ្គង់សេវាកម្ម ចំពោះករណីនីតិវិធីផ្តល់អាជ្ញាប័ណ្ណ។

៥. (ក) ចំពោះវិស័យ ដែលភាគីណាមួយបានធ្វើការសន្យាដាក់លាក់នៅក្រោមផ្នែកទី៣ នៃកិច្ចព្រមព្រៀងនេះ ដោយរង់ចាំបញ្ចូលបន្ថែមនូវវិន័យទាំងឡាយដែលមានចែងក្នុងកថាខណ្ឌទី៤ នៃមាត្រានេះ ភាគីនោះមិនត្រូវប្រើប្រាស់លក្ខណ្ឌអាជ្ញាប័ណ្ណ លក្ខខណ្ឌគុណវុឌ្ឍិ និងបទដ្ឋានបច្ចេកទេសនានាដែលធ្វើឲ្យមោឃៈ ឬ ប៉ះពាល់ដល់កាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងនេះ ក្នុងលក្ខណៈមួយដែល៖

i. មិនស្របតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងកថាខណ្ឌទី៤(ក) (ខ) ឬ (គ) នៃមាត្រានេះ និង

ii. មិនអាចត្រូវបានរំពឹងទុកមុនពីសំណាក់ភាគីនោះ នៅពេលដែលការសន្យាដាក់លាក់ទាំងនោះត្រូវបានធ្វើឡើង។

(ខ) ដើម្បីកំណត់ថាតើភាគីមួយអនុវត្តស្របតាមកាតព្វកិច្ច ដូចដែលមានចែងក្នុងកថាខណ្ឌទី៥(ក) នៃមាត្រានេះ បទដ្ឋានអន្តរជាតិរបស់អង្គការអន្តរជាតិពាក់ព័ន្ធនានា[6] ដែលភាគីនោះបានអនុវត្តត្រូវយកមកពិចារណា។

៦. ចំពោះវិស័យដែលការសន្យាដាក់លាក់ពាក់ព័ន្ធនឹងសេវាកម្មវិជ្ជាជីវៈ ភាគីនីមួយៗត្រូវផ្តល់នីតិវិធីគ្រប់គ្រាន់ដើម្បីផ្ទៀងផ្ទាត់សមត្ថភាពជំនាញវិជ្ជាជីវៈរបស់ភាគីមួយផ្សេងទៀត ស្របតាមបទបញ្ញត្តិដូចមានក្នុងកថាខណ្ឌទី៥ នៃមាត្រានេះ ។

មាត្រា ៦
ការទទួលស្គាល់

[6] ពាក្យ "អង្គការអន្តរជាតិពាក់ព័ន្ធនានា" សំដៅលើស្ថាប័នអន្តរជាតិនានា ដែលសមាជិកភាពរបស់ខ្លួនត្រូវបានបើកចំពោះស្ថាប័នពាក់ព័ន្ធរបស់បណ្តាភាគីទាំងអស់នៃកិច្ចព្រមព្រៀងនេះ ។

១. ក្នុងគោលបំណងបំពេញតាមបទដ្ឋាន ឬ លក្ខណៈវិនិច្ឆ័យ ក្នុងការផ្តល់សិទ្ធិអនុញ្ញាត អាជ្ញាប័ណ្ណ ឬ វិញ្ញាបនប័ត្រដល់អ្នកផ្តត់ផ្តង់សេវាកម្ម ភាគីនីមួយៗអាចទទួលស្គាល់ការអប់រំ ឬ បទពិសោធន៍ដែលទទួលបាន ការបំពេញបានតាមលក្ខខណ្ឌតម្រូវផ្សេងៗ អាជ្ញាប័ណ្ណ ឬ វិញ្ញាបនប័ត្រ ដែលត្រូវបានផ្តល់ជូនក្នុងប្រទេសរបស់ ភាគីមួយទៀត ។ ការទទួលស្គាល់បែបនេះ អាចនឹងធ្វើទៅបានតាមរយៈសុខដុមនីយកម្ម ឬ អាចផ្អែកលើកិច្ច ព្រមព្រៀង ឬការរៀបចំរវាងបណ្តាភាគី ឬ ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ឬ អាចត្រូវបានផ្តល់ដោយស្វយ័ត ។

២. ភាគីមួយដែលជាភាគីនៃកិច្ចព្រមព្រៀង ឬការរៀបចំដែលមានចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះទោះជា ពេលបច្ចុប្បន្ន ឬ អនាគតក្តី ត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដល់បណ្តាភាគីពាក់ព័ន្ធ ដែលមានចំណាប់អារម្មណ៍ ក្នុង ការចរចាចូលជាសមាជិកក្នុងកិច្ចព្រមព្រៀង ឬ ការរៀបចំបែបនេះ ឬ កិច្ចព្រមព្រៀង ឬ ការរៀបចំផ្សេងទៀតដែល មានលក្ខណៈប្រហាក់ប្រហែលគ្នា។ នៅពេលដែលភាគីមួយទទួលស្គាល់ដោយស្វយ័ត ភាគីនោះត្រូវផ្តល់ ឱកាសគ្រប់គ្រាន់ដល់ភាគីផ្សេងទៀតដើម្បីបង្ហាញថា ការអប់រំ បទពិសោធន៍ អាជ្ញាប័ណ្ណ ឬ វិញ្ញាបនប័ត្រដែល ទទួលបាន ឬ ដែលបំពេញបានតាមលក្ខខណ្ឌតម្រូវនោះក្នុងដែនដីរបស់ភាគីជទៃទៀត ក៏នឹងត្រូវបានទទួល ស្គាល់ផងដែរ។

៣. នៅពេលទទួលបានសំណើជាលាយលក្ខអក្សរពីភាគីមួយ ភាគីទទួលសំណើត្រូវជំរុញស្ថាប័នជំនាញពាក់ ព័ន្ធ ឬ អាជ្ញាធរជំនាញទាក់ទងបទប្បញ្ញត្តិ ក្នុងវិស័យសេវាកម្មនានាដែលផ្តល់ផលប្រយោជន៍ទាំងសងខាង ឲ្យចរចា និងបញ្ចប់ការទទួលស្គាល់ទៅវិញទៅមកលើការអប់រំ បទពិសោធន៍ អាជ្ញាប័ណ្ណ ឬ វិញ្ញាបនប័ត្រ ឬ លក្ខខណ្ឌតម្រូវផ្សេងៗសម្រាប់វិស័យសេវាកម្មនោះក្នុងរយៈពេល១២ខែ ឬ ក្នុងរយៈពេលកំណត់សមស្របមួយ ដែលព្រមព្រៀងដោយស្ថាប័នជំនាញរបស់ភាគីទាំងពីរ ក្នុងគោលដៅសម្រេចលទ្ធផលឲ្យបានឆាប់។ រាល់ការ ពន្យាពេល ឬ ការបរាជ័យរបស់ស្ថាប័នជំនាញជំនាញក្នុងការសម្រេចកិច្ចព្រមព្រៀង ឬ ការរៀបចំទាំងឡាយនោះ នឹងមិនត្រូវចាត់ទុកថាជាការបំពានលើកាតព្វកិច្ចរបស់ភាគីមួយ ដែលមានចែងក្នុងកថាខណ្ឌនេះ និងមិនត្រូវ យកទៅអនុវត្តនៅក្នុងកិច្ចព្រមព្រៀងអាស៊ាន-ឥណ្ឌាស្តីពីយន្តការដោះស្រាយវិវាទក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ អាស៊ាន-ឥណ្ឌាឡើយ។ វឌ្ឍនភាពនានាពាក់ព័ន្ធនឹងបញ្ហានេះ នឹងត្រូវពិនិត្យឡើងវិញដោយបណ្តាភាគីនៃកិច្ច ព្រមព្រៀងនេះ ដូចមានចែងក្នុងមាត្រា២៧ (ការពិនិត្យឡើងវិញ) ។

៤. ក្នុងករណី សុខដុមនីយកម្មកិច្ចព្រមព្រៀង ឬការរៀបចំ ដូចមានចែងក្នុងកថាខណ្ឌទី១ ទី២ និងទី៣ នៃ មាត្រានេះមិនអាចធ្វើទៅរួច ភាគីនីមួយៗត្រូវអនុញ្ញាតឲ្យស្ថាប័ន ឬ អាជ្ញាធរច្បាប់ជំនាញពាក់ព័ន្ធ ធ្វើការ ពិចារណាក្នុងការផ្តល់អាជ្ញាប័ណ្ណ ឬ ការទទួលស្គាល់ទៅវិញទៅមក ក្នុងដែនដីរបស់ខ្លួនស្របតាមច្បាប់ និង បទប្បញ្ញត្តិរបស់ប្រទេសជាម្ចាស់ផ្ទះ។

៥. ភាគីមួយមិនត្រូវផ្តល់ការទទួលស្គាល់ក្នុងលក្ខណៈរើសអើងរវាងប្រទេសនានា នៅក្នុងការអនុវត្តបទដ្ឋាន ឬលក្ខណៈវិនិច្ឆ័យរបស់ខ្លួនក្នុងការផ្តល់សិទ្ធិអនុញ្ញាត អាជ្ញាប័ណ្ណ ឬវិញ្ញាបនប័ត្រ ដល់អ្នកផ្តត់ផ្តង់សេវាកម្ម ឬ ការ រឹតត្បឹតជាលក្ខណៈបិទបាំង ចំពោះពាណិជ្ជកម្មសេវាកម្មឡើយ។

៦. បណ្តាភាគីឯកភាពថា នឹងមិនទទួលខុសត្រូវចំពោះការដោះស្រាយជម្លោះដែលកើតមានឡើងនៅក្រៅ ឬក្រោមកិច្ចព្រមព្រៀង ឬ ការរៀបចំ ក្នុងការទទួលស្គាល់ទៅវិញទៅមកណាមួយ ដែលសម្រេចដោយស្ថាប័ន ឬ អាជ្ញាធរជំនាញបទប្បញ្ញត្តិរបស់ខ្លួន ដូចមានចែងក្នុងបទប្បញ្ញត្តិនៃមាត្រានេះ និង បទប្បញ្ញត្តិទាំងឡាយនៅ

ក្រោមកិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយវិវាទអាស៊ាន-ឥណ្ឌា នឹងមិនត្រូវអនុវត្តយកមកអនុវត្តចំពោះជម្លោះដែលកើតឡើងនៅក្រៅ ឬ ក្រោមកិច្ចព្រមព្រៀង ឬការរៀបចំនេះទេ ។

មាត្រា ៧
ឯកាធិការ និងការផ្តត់ផ្តង់សេវាកម្មផ្តាច់មុខ

១. ភាគីនីមួយៗត្រូវធានាថា អ្នកផ្តត់ផ្តង់សេវាកម្មផ្តាច់មុខណាមួយនៅក្នុងដែនដីរបស់ខ្លួន នឹងមិនប្រព្រឹត្តទៅក្នុងលក្ខណៈមួយដែលមិនស្របតាមកាតព្វកិច្ចរបស់ខ្លួន ក្រោមការសន្យាជាក់លាក់ ក្នុងការផ្តត់ផ្តង់សេវាកម្មផ្តាច់មុខក្នុងទីផ្សារពាក់ព័ន្ធនានាឡើយ។

២. នៅពេលដែលអ្នកផ្តត់ផ្តង់ផ្តាច់មុខរបស់ភាគីមួយប្រកួតប្រជែងដោយផ្ទាល់ ឬ តាមរយៈក្រុមហ៊ុនបុត្រសម្ព័ន្ធក្នុងការផ្តត់ផ្តង់សេវាកម្មដែលស្ថិតក្រៅវិសាលភាពនៃសិទ្ធិផ្តាច់មុខរបស់ខ្លួន និងជាការសន្យាជាក់លាក់របស់ភាគីនោះ ភាគីនោះត្រូវធានាថាអ្នកផ្តត់ផ្តង់ នឹងមិនបំពានលើតួនាទីផ្តាច់មុខរបស់ខ្លួនក្នុងការផ្តត់ផ្តង់នៅក្នុងដែនដីរបស់ខ្លួន ក្នុងលក្ខណៈមួយដែលមិនស្របនឹងការសន្យាទាំងនោះ ។

៣. ប្រសិនបើភាគីណាមួយមានហេតុផលដែលគួរឲ្យជឿជាក់ថា អ្នកផ្តត់ផ្តង់សេវាកម្មផ្តាច់មុខនៃភាគីមួយផ្សេងទៀតកំពុងតែប្រព្រឹត្តមិនស្របទៅនឹងបទប្បញ្ញត្តិដែលមានចែងក្នុងកថាខណ្ឌ១ ឬ ២ នៃមាត្រានេះ ភាគីនោះអាចស្នើភាគីមួយទៀត ក្នុងការបង្កើត រក្សាទុក ឬ ផ្តល់សិទ្ធិអនុញ្ញាតឲ្យអ្នកផ្តត់ផ្តង់សេវាកម្មនោះ ផ្តល់ពត៌មានជាក់លាក់អំពីប្រតិបត្តិការពាក់ព័ន្ធរបស់ខ្លួនបាន។

៤. បទប្បញ្ញត្តិនានានៃមាត្រានេះ ក៏ត្រូវអនុវត្តផងដែរចំពោះករណីដែលអ្នកផ្តត់ផ្តង់សេវាកម្មផ្តាច់មុខដែលភាគីមួយ ៖

(ក) ផ្តល់សិទ្ធិអនុញ្ញាត ឬ បង្កើតអ្នកផ្តត់ផ្តង់សេវាកម្មមួយក្រុមតូច និង

(ខ) ការពារស្ទើរតែទាំងស្រុងមិនឲ្យមានការប្រកួតប្រជែងក្នុងចំណោមអ្នកផ្តត់ផ្តង់ទាំងនោះក្នុងដែនដីរបស់ខ្លួន។

មាត្រា ៨
ការអនុវត្តធុរកិច្ច

១. បណ្តាភាគីទទួលស្គាល់ថា ការអនុវត្តធុរកិច្ចមួយចំនួនរបស់អ្នកផ្តត់ផ្តង់សេវាកម្ម ក្រៅពីការអនុវត្តដែលមានចែងក្នុងមាត្រា៧ (ឯកាធិការ និងការផ្តត់ផ្តង់សេវាកម្មផ្តាច់មុខ) អាចបង្កាក់ការប្រកួតប្រជែង និងរឹតបន្តឹងដល់ពាណិជ្ជកម្មសេវាកម្ម។

២. ផ្ទៃកតាមសំណើរបស់ភាគីមួយផ្សេងទៀត ភាគីនីមួយៗត្រូវចូលរួមពិគ្រោះយោបល់ក្នុងគោលបំណងលុបបំបាត់ការអនុវត្តនានាដូចមានចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ។ ភាគីដែលត្រូវបានស្នើសុំត្រូវពិចារណាឲ្យបានពេញលេញ និងប្រកបដោយសមានចិត្តចំពោះសំណើនោះ និងត្រូវសហការតាមរយៈការផ្តល់ព័ត៌មានមិនសម្ងាត់ ដែលអាចរកបានជាសាធារណៈទាក់ទងនឹងបញ្ហាដែលជាកម្មវត្ថុនោះ។ ភាគីដែលត្រូវបានស្នើសុំក៏ត្រូវផ្តល់ផងដែរនូវព័ត៌មានដែលអាចរកបានដទៃទៀតតាមសំណើរបស់ភាគីស្នើសុំ យោងតាមច្បាប់ក្នុងស្រុករបស់ខ្លួន និងអាស្រ័យលើការព្រមព្រៀងគ្នាទាក់ទងនឹងការការពារព័ត៌មានសម្ងាត់របស់ខ្លួន ដោយភាគីស្នើសុំ។

មាត្រា ៩
ការការពារ

១. បណ្តាភាគីកត់សម្គាល់អំពីកិច្ចចរចាពហុភាគីអនុលោមតាមមាត្រា X នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្ម សេវាកម្ម(GATS)លើពីវិធានការការពារក្នុងសភាពបន្ទាន់ផ្អែកលើគោលការណ៍មិនរើសអើង។ នៅពេលបញ្ចប់កិច្ចចរចាពហុភាគីទាំងនោះ បណ្តាភាគីត្រូវធ្វើការពិនិត្យឡើងវិញក្នុងគោលបំណងពិភាក្សាអំពីការធ្វើវិសោធនកម្ម ដែលសមស្រប ចំពោះកិច្ចព្រមព្រៀងនេះ ដើម្បីបញ្ចូលនូវលទ្ធផលទាំងឡាយនៃកិច្ចចរចាពហុភាគីនោះ។ រហូតដល់ពេលដែលការចរចាពហុភាគីទាំងនោះបានបញ្ចប់ គ្មានភាគីណាមួយចាត់វិធានការការពារខ្លួនប្រឆាំងនឹងសេវាកម្ម និងអ្នកផ្តត់ផ្តង់សេវាកម្មរបស់ភាគីមួយ ឬ របស់បណ្តាភាគីដទៃទៀត លើកលែងតែអនុលោមតាមនីតិវិធី ដូចមានចែងលំអិតក្នុងកថាខណ្ឌ២ នៃមាត្រានេះ។

២. នៅក្នុងករណីដែលការអនុវត្តកិច្ចព្រមព្រៀងនេះ បណ្តាលឲ្យប៉ះពាល់ធ្ងន់ធ្ងរទៅលើវិស័យសេវាកម្មរបស់ភាគីមួយ នៅមុនការបញ្ចប់កិច្ចចរចាពហុភាគីដូចមានចែងក្នុងកថាខណ្ឌ១នៃមាត្រានេះ ភាគីដែលរងការប៉ះពាល់អាចស្នើសុំឲ្យមានកិច្ចពិគ្រោះយោបល់ជាមួយភាគីដទៃទៀត ឬបណ្តាភាគីដទៃទៀត ដើម្បីពិភាក្សាលើការចាត់វិធានការការពារនានានៃវិស័យសេវាកម្មដែលរងការប៉ះពាល់នោះ។ វិធានការណាមួយ ដែលធ្វើឡើងដោយអនុលោមតាមកថាខណ្ឌនេះ រួមទាំងរយៈពេលសម្រាប់អនុវត្តវិធានការនោះ ត្រូវតែមានការព្រមព្រៀងគ្នាទៅវិញទៅមកដោយបណ្តាភាគីពាក់ព័ន្ធ និងត្រូវអនុវត្តផ្អែកលើគោលការណ៍មិនរើសអើង និងចំពោះវិស័យសេវាកម្មជាក់លាក់ប៉ុណ្ណោះ។ បណ្តាភាគីពាក់ព័ន្ធត្រូវគិតគូរដោយផ្អែកលើកាលៈទេសៈជាក់ស្តែងរបស់ករណីនោះ និងផ្តល់នូវការពិចារណាប្រកបដោយសមានចិត្ត ចំពោះភាគីដែលស្នើសុំចាត់វិធានការនោះ។

មាត្រា ១០
ការទូទាត់ និងការផ្ទេរ

១. លើកលែងតែស្ថិតក្រោមកាលៈទេសៈដែលត្រូវបានប្រមើលទុកមុននៅក្នុងមាត្រា១១ (ការពិតបន្តឹងដើម្បីការពារតុល្យភាពនៃការទូទាត់) ភាគីមួយមិនត្រូវដាក់ពិតបន្តឹងចំពោះការផ្ទេរ និងការទូទាត់ជាអន្តរជាតិ សម្រាប់ប្រតិបត្តិការចរន្តទាំងឡាយពាក់ព័ន្ធនឹងការសន្យាជាក់លាក់របស់ខ្លួន។

២. កិច្ចព្រមព្រៀងនេះពុំមានប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីណាមួយដែលជាសមាជិកនៃអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ក្រោមមាត្រាក្រោមកិច្ចព្រមព្រៀងមូលនិធិ ដោយរួមបញ្ចូលទាំងសកម្មភាពដោះដូរ ដែលអនុលោមតាមមាត្រានៃកិច្ចព្រមព្រៀងមូលនិធិនេះ ក្នុងករណីភាគីមួយមិនជាក់ការពិតបន្តឹងលើប្រតិបត្តិការមូលធនទាំងឡាយណាដែលមិនសមស្របនឹងការសន្យាជាក់លាក់ ពាក់ព័ន្ធនឹងប្រតិបត្តិការទាំងនេះលើកលែងតែមានចែងក្នុងមាត្រា១១ (ការពិតបន្តឹងដើម្បីការពារតុល្យភាពនៃការទូទាត់) ឬ ផ្អែកតាមសំណើរបស់មូលនិធិ។

មាត្រា ១១
ការពិតបន្តឹងដើម្បីការពារតុល្យភាពនៃការទូទាត់

ក្នុងករណីដែលភាគីមួយមានបញ្ហាតុល្យភាពនៃការទូទាត់ធ្ងន់ធ្ងរ និងជួបការលំបាកផ្នែកហិរញ្ញវត្ថុ ឬ មានការគំរាមកំហែងផ្សេងៗ ភាគីនោះអាចអនុម័ត ឬ រក្សាការពិតបន្តឹងលើពាណិជ្ជកម្មសេវាកម្ម ដោយអនុលោមតាមកថាខណ្ឌ ១, ២ និង៣ នៃមាត្រា XII របស់កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម (GATS)។

មាត្រា ១២
ការលើកលែងទូទៅ

យោងទៅលើលក្ខខណ្ឌចែងថា វិធានការបែបនេះមិនត្រូវបានអនុវត្តក្នុងលក្ខណៈរើសអើងស្រេចតែអំពើចិត្ត ឬ អយុត្តិធម៌រវាងបណ្តាភាគីដែលមានលក្ខខណ្ឌដូចគ្នា ឬ រឹតបន្តឹងដោយបិទបាំងលើពាណិជ្ជកម្មសេវាកម្ម កិច្ចព្រមព្រៀងនេះ ពុំអាចត្រូវបានបកស្រាយដើម្បីរារាំងដល់ការអនុម័ត ឬ ការអនុវត្តដោយភាគីណាមួយ នូវបណ្តាវិធានការដែល៖

(ក) ចាំបាច់សម្រាប់ការពារក្រមសីលធម៌សាធារណៈ ឬ ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ;[៧]

(ខ) ចាំបាច់សម្រាប់ការពារសុខភាព ឬ ជីវិតមនុស្ស សត្វ ឬ រុក្ខជាតិ

(គ) ចាំបាច់សម្រាប់ធានាឲ្យមានអនុលោមភាពស្របតាមច្បាប់ ឬ តាមបទប្បញ្ញត្តិទាំងឡាយដែលមិនផ្ទុយពីបទប្បញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ រួមបញ្ចូលទាំងវិធានការពាក់ព័ន្ធនឹង៖

i. ការទប់ស្កាត់ការអនុវត្តបែបឆបោកនិងក្លែងបន្លំ ឬ ចាត់វិធានការទប់ទល់នឹងការខកខានមិនបានបំពេញតាមកិច្ចសន្យាសេវាកម្ម។

ii. ការការពារនូវការសម្ងាត់របស់បុគ្គលម្នាក់ៗពាក់ព័ន្ធនឹងការដំណើរការ និងការផ្សព្វផ្សាយព័ត៌មានផ្ទាល់ខ្លួន និងការការពារការសម្ងាត់របស់គណនី និងប្រវត្តិរូបផ្ទាល់ខ្លួន។

iii. សុវត្ថិភាព។

(ឃ) មិនអនុលោមតាមមាត្រា១៨(ប្រព្រឹត្តិកម្មជាតិ) ក្នុងករណីភាពខុសគ្នាក្នុងប្រព្រឹត្តិកម្មនោះធ្វើឡើងក្នុងគោលបំណងដើម្បីធានាបាននូវការដាក់បន្ទុក ឬ ការប្រមូលពន្ធផ្ទាល់ ប្រកបដោយសមធម៌ ឬ ប្រសិទ្ធភាព[៦] ទាក់ទងនឹងសេវាកម្ម ឬ អ្នកផ្តត់ផ្គង់សេវាកម្មរបស់ភាគីដទៃទៀត។

---

[៧] ការលើកលែងសណ្តាប់ធ្នាប់សាធារណៈ អាចត្រូវបានយកមកប្រើ ចំពោះតែករណីមានការគេម្រាមគំហែងពិតប្រាកដ ឬធ្ងន់ធ្ងរគ្រប់គ្រាន់ណាមួយបង្កឲ្យប៉ះពាល់ដល់ផលប្រយោជន៍ណាមួយក្នុងចំណោមផលប្រយោជន៍មូលដ្ឋាននានារបស់សង្គម។

[៦] វិធានការដែលមានគោលដៅធានាការដាក់ ឬការប្រមូលពន្ធផ្ទាល់ប្រកបដោយសមធម៌ ឬប្រសិទ្ធិភាព រួមបញ្ចូលទាំងវិធានការដែលអនុវត្តដោយភាគីណាមួយក្រោមប្រព័ន្ធពន្ធអាកររបស់ខ្លួន ដែល៖

i. អនុវត្តចំពោះអ្នកផ្តត់ផ្គង់សេវាកម្មដែលមិនមែនជានិវេសនជន ដោយទទួលស្គាល់ជាក់ស្តែងថាភាតព្វកិច្ចពន្ធរបស់អនិវេសនជន គឺត្រូវបានកំណត់ស្របទៅតាមវត្ថុធាតុទាំងឡាយដែលអាចជាប់ពន្ធ ហើយដែលមានប្រភព ឬស្ថិតនៅក្នុងដែនដីរបស់ភាគីនោះ ឬ

ii. អនុវត្តចំពោះអនិវេសនជន ដើម្បីធានានូវការដាក់ ឬការប្រមូលពន្ធក្នុងដែនដីរបស់ភាគីនោះ ឬ

iii. អនុវត្តចំពោះអនិវេសនជន ឬនិវេសនជន ដើម្បីរារាំងការចៀសវាង ឬការគេចវេសពីការបង់ពន្ធ រួមទាំងវិធានការអនុលោមភាព ឬ

iv. អនុវត្តចំពោះអ្នកប្រើប្រាស់សេវាកម្ម ដែលសេវាកម្មនោះត្រូវបានផ្តត់ផ្គង់ក្នុង ឬមកពីដែនដីរបស់ភាគីដទៃទៀត ដើម្បីធានានូវការដាក់ ឬការប្រមូលពន្ធពីអ្នកប្រើប្រាស់សេវាកម្មបែបនេះ ដែលបានពីប្រភពនៅក្នុងដែនដីរបស់ភាគីនោះ ឬ

v. បង្ហាញពីភាពខុសគ្នារវាង អ្នកផ្តត់ផ្គង់សេវាកម្មទាំងឡាយដែលផ្អែកលើវត្ថុធាតុទាំងឡាយដែលអាចជាប់ពន្ធទូទាំងពិភពលោក ពីអ្នកផ្តត់ផ្គង់សេវាកម្មផ្សេងទៀត ដោយទទួលស្គាល់ពីភាពខុសគ្នានៃអនាគតរបស់មូលដ្ឋានពន្ធរវាងពួកគេ ឬ

vi. កំណត់នូវ ចំណូលដែលត្រូវបម្រុងទុកឬត្រូវបែងចែក ផលចំណេញ កំណើន កំហាត ការដេកហូតឬឥណទានរបស់បុគ្គលជានិវេសនជន ឬ សាខា, ឬ រវាងបុគ្គល ឬសាខាពាក់ព័ន្ធនឹងបុគ្គលជាដែលនេះ ដើម្បីការពារមូលដ្ឋានពន្ធរបស់ភាគីនោះ ។

(ង) ជាលទ្ធផលខុសគ្នានៅក្នុងប្រព្រឹត្តិកម្ម ដែលកើតឡើងមកពីកិច្ចព្រមព្រៀង ស្តីពីការជៀសវាងការយកពន្ធត្រួតគ្នា ឬ បទប្បញ្ញត្តិនានាស្តីពីការជៀសវាងការយកពន្ធត្រួតគ្នា នៅក្នុងកិច្ចព្រមព្រៀង ឬ ការរៀបចំអន្តរជាតិទាំងឡាយ ដែលភាគីនោះជាប់កាតព្វកិច្ច។

មាត្រា ១៣
ការលើកលែងផ្តែកសន្តិសុខ

១. កិច្ចព្រមព្រៀងនេះ ពុំត្រូវបានបកស្រាយដើម្បី៖

(ក) តម្រូវឲ្យភាគីណាមួយផ្តល់ពត៌មាន ដែលផ្ទុយនឹងផលប្រយោជន៍សំខាន់ៗពាក់ព័ន្ធនឹងសន្តិសុខ

(ខ) រារាំងភាគីណាមួយមិនឲ្យចាត់វិធានការចាំបាច់សម្រាប់ការពារផលប្រយោជន៍សំខាន់ៗពាក់ព័ន្ធនឹងសន្តិសុខរបស់ខ្លួន ដោយរួមបញ្ចូល៖

i. សកម្មភាពពាក់ព័ន្ធនឹងសម្ភារៈដែលអាចផ្ទុះ ឬអាចឆេះ ឬ សម្ភារៈនានាដែលកើតចេញពីសារធាតុទាំងនេះ

ii. សកម្មភាពពាក់ព័ន្ធនឹងការចរាចរសព្វាវុធ គ្រាប់រំសេវ និងសំភារៈសង្គ្រាម និងការចរាចរទំនិញ និងសំភារៈដទៃទៀតដោយផ្ទាល់ ឬប្រយោលក្នុងគោលបំណងផ្តត់ផ្តង់ដល់ការបង្កើតកងកម្លាំងប្រដាប់អាវុធ

iii. សកម្មភាពដែលធ្វើឡើងសំដៅការពារហេដ្ឋារចនាសម្ព័ន្ធសាធារណៈសំខាន់ៗ រួមមានហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ថាមពល និងធារាសាស្ត្រ ពីការប៉ុនប៉ងធ្វើឲ្យខូចខាត ឬបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធទាំងនោះ

iv. សកម្មភាពដែលធ្វើឡើងនៅពេលមានសង្គ្រាម ឬ ក្នុងស្ថានភាពអាសន្ននៃទំនាក់ទំនងក្នុងប្រទេស ឬ អន្តរជាតិ ឬ

(គ) រារាំងភាគីណាមួយមិនឲ្យចាត់វិធានការណា ស្របតាមភាតព្វកិច្ចរបស់ខ្លួនតាមធម្មនុញ្ញអង្គការសហប្រជាជាតិ ដើម្បីរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ។

២. ភាគីនីមួយៗ ត្រូវជូនព័ត៌មានដល់ភាគីដទៃទៀតឲ្យបានពេញលេញតាមដែលអាចធ្វើទៅបាន អំពីវិធានការនានា ដែលត្រូវបានអនុវត្ត ដូចមានចែងក្នុងកថាខណ្ឌ១ (ខ) និង ១ (គ) នៃមាត្រានេះ ព្រមទាំងការបញ្ចប់វិធានការទាំងនោះផងដែរ។

៣. កិច្ចព្រមព្រៀងនេះពុំត្រូវបានបកស្រាយ ដើម្បីឲ្យភាគីណាមួយផ្តល់ផលប្រយោជន៍នៃកិច្ចព្រមព្រៀងនេះដល់អ្នកផ្តត់ផ្តង់សេវាកម្មនៃភាគីដទៃទៀត ក្នុងករណីភាគីណាមួយនោះអនុម័ត ឬ រក្សា នូវវិធានការនៅក្នុងច្បាប់ ឬ បទប្បញ្ញត្តិដែលចាំបាច់ ដើម្បីការពារផលប្រយោជន៍សំខាន់ៗពាក់ព័ន្ធនឹងសន្តិសុខរបស់ខ្លួនទៅឲ្យភាគី ឬអ្នកផ្តត់ផ្តង់សេវាកម្មនៃភាគីមិនស្ថិតនៅក្រោមកិច្ចព្រមព្រៀង ដែលអាចត្រូវបានរំលោភបំពាន ឬ ក្លែងបន្លំ ប្រសិនបើផលប្រយោជន៍នៃកិច្ចព្រមព្រៀងនេះ ត្រូវបានផ្តល់ដល់អ្នកផ្តត់ផ្តង់សេវាកម្មនោះ។

លក្ខខណ្ឌ ឬទស្សនទានពន្ធទាំងឡាយ ដែលនៅក្នុងកថាខណ្ឌរង (ឃ) នៃមាត្រានេះ និងនៅក្នុងលេខយោងនេះ ត្រូវបានកំណត់ដោយអាស្រ័យតាមនិយមន័យ និងទស្សនទានពន្ធ, ឬនិយមន័យ និងទស្សនទាន ដែលមានតម្លៃស្មើ ឬប្រហាក់ប្រហែល ស្ថិតនៅក្រោមច្បាប់ក្នុងស្រុករបស់ភាគី ដែលអនុវត្តវិធានការនេះ ។

មាត្រា ១៤
ឧបត្ថម្ភធន

១. លើកលែងតែមានចែងនៅក្នុងមាត្រានេះ កិច្ចព្រមព្រៀងនេះមិនត្រូវអនុវត្តចំពោះឧបត្ថម្ភធន ឬ ជំនួយផ្សេងៗដែលផ្តល់ដោយភាគីណាមួយ ឬ ចំពោះលក្ខខណ្ឌទាំងឡាយណា ដែលភ្ជាប់ជាមួយនឹងការទទួល ឬ ការបន្តទទួលឧបត្ថម្ភធន ឬ ជំនួយបែបនេះឡើយ បើទោះបីជាឧបត្ថម្ភធន ឬ ជំនួយទាំងនោះត្រូវបានផ្តល់ ឬមិនត្រូវបានផ្តល់ទាំងស្រុងដល់សេវាកម្មក្នុងស្រុក អ្នកប្រើប្រាស់សេវាកម្ម ឬអ្នកផ្គត់ផ្គង់សេវាកម្មក៏ដោយ។ ក្នុងករណីឧបត្ថម្ភធន ឬ ជំនួយទាំងនោះជះឥទ្ធិពលលើពាណិជ្ជកម្មសេវាកម្មដែលបានសន្យានៅក្នុងកិច្ចព្រមព្រៀងនេះ ភាគីណាមួយ អាចស្នើសុំកិច្ចពិគ្រោះយោបល់ ដើម្បីរកដំណោះស្រាយប្រកបដោយមិត្តភាពចំពោះបញ្ហានេះ។

២. ដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ បណ្តាភាគីត្រូវ៖

(ក) ផ្តល់ព័ត៌មានស្តីពីឧបត្ថម្ភធនពាក់ព័ន្ធនឹងពាណិជ្ជកម្មសេវាកម្ម ដែលបានសន្យានៅក្នុងកិច្ចព្រមព្រៀងនេះ ជូនដល់ភាគីស្នើសុំ ដោយផ្អែកតាមការស្នើ និង

(ខ) ពិនិត្យឡើងវិញនូវប្រព្រឹត្តិកម្មនៃឧបត្ថម្ភធន នៅពេលដែលវិន័យពាក់ព័ន្ធនានាត្រូវបានបង្កើតឡើង ដោយអង្គការពាណិជ្ជកម្មពិភពលោក។

៣. បទប្បញ្ញត្តិនានានៃកិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយវិវាទអាស៊ាន-ឥណ្ឌា (ASEAN-India DSM Agreement) នឹងមិនត្រូវបានយកមកអនុវត្តចំពោះការស្នើសុំ ឬ កិច្ចពិគ្រោះយោបល់ណាមួយ ដែលត្រូវបានធ្វើឡើងក្រោមប្រការនានានៃមាត្រានេះ ឬ ចំពោះវិវាទណាមួយដែលអាចកើតឡើងរវាងបណ្តាភាគីដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃមាត្រានេះ។

មាត្រា ១៥
កិច្ចសហប្រតិបត្តិការ

បណ្តាភាគីត្រូវពង្រឹងកិច្ចសហប្រតិបត្តិការនៅក្នុងវិស័យសេវាកម្ម រួមបញ្ចូលទាំងវិស័យនានាដែលមិនត្រូវបានគ្របដណ្តប់ក្នុងកិច្ចសហប្រតិបត្តិការដែលមានពីមុន។ បណ្តាភាគីត្រូវពិភាក្សា និងឯកភាពទៅវិញទៅមកនៅលើវិស័យនានាសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍកម្មវិធីកិច្ចសហប្រតិបត្តិការក្នុងវិស័យទាំងនេះសំដៅកែលម្អសមត្ថភាព ប្រសិទ្ធភាព និងការប្រកួតប្រជែងក្នុងស្រុករបស់ខ្លួន។

មាត្រា ១៦
ការបង្កើនការចូលរួមរបស់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម

១. ការបង្កើនការចូលរួមរបស់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាមនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានសម្របសម្រួលតាមរយៈការចរចាលើការសន្យាជាក់លាក់ ដែលពាក់ព័ន្ធនឹង៖

(ក) ការពង្រឹងសមត្ថភាពសេវាកម្មក្នុងស្រុក ប្រសិទ្ធភាព និងភាពប្រកួតប្រជែងរបស់ពួកគេ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យា ឈរលើមូលដ្ឋានពាណិជ្ជកម្ម

(ខ) ការកែលម្អការប្រើប្រាស់មធ្យោបាយចែកចាយ និងបណ្តាញព័ត៌មាន ឈរលើមូលដ្ឋានពាណិជ្ជកម្ម និង

(គ) ការធ្វើសេរីភាវូបនីយកម្មច្រកចូលទីផ្សារនៃវិស័យនានា និងវិធីសាស្ត្រនៃការផ្តត់ផ្តង់សម្រាប់នាំចេញដែលមានអត្ថប្រយោជន៍ ដល់ពួកគេ។

២. កាពទន់ភ្លន់សមស្របត្រូវបានផ្តល់ ចំពោះប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាមសម្រាប់ការធ្វើសេរីភាវូបនីយកម្មឲ្យកាន់តែល្អប្រសើរ លើការអនុវត្តការសន្យាជាក់លាក់ស្របតាមដំណាក់កាលនៃការអភិវឌ្ឍរៀងៗខ្លួន។

ផ្នែកទី ៣ ៖ ការសន្យាជាក់លាក់

មាត្រា១៧

ការបើកច្រកទីផ្សារ

១. ចំពោះការបើកច្រកទីផ្សារតាមរយៈ វិធីសាស្ត្រផ្តត់ផ្តង់សេវាកម្មដែលមានចែងនៅក្នុងកថាខ័ណ្ឌ (កក) នៃមាត្រា២ (និយមន័យ) នៃកិច្ចព្រមព្រៀងនេះ ភាគីមួយត្រូវផ្តល់ប្រព្រឹត្តិកម្មដល់សេវាកម្ម និងអ្នកផ្តត់ផ្តង់សេវាកម្មរបស់ភាគីដទៃទៀត មិនតិចជាងអ្វីដែលបានកំណត់នៅក្នុងលក្ខខណ្ឌ ដែនកំណត់នានាដែលបានឯកភាពគ្នា និងដែលមានចែងច្បាស់លាស់នៅក្នុងតារាងនៃការសន្យារបស់ខ្លួន ។[៧]

២. ក្នុងវិស័យទាំងឡាយណា ដែលការសន្យាលើការបើកច្រកទីផ្សារត្រូវបានអនុវត្ត វិធានការនានាដែលភាគីមួយមិនត្រូវប្រើប្រាស់ ឬអនុម័ត ទោះជាក្នុងផ្នែកមួយរបស់តំបន់ ឬដែនដីទាំងមូលរបស់ខ្លួនក្តី លុះត្រាតែបានបញ្ជាក់ច្បាស់លាស់ក្នុងតារាងសន្យារបស់ខ្លួន ត្រូវបានកំណត់ដូចខាងក្រោម៖

(ក) ការកំណត់លើចំនួនអ្នកផ្តត់ផ្តង់សេវាកម្ម ទោះជាក្នុងទម្រង់កូតាចំនួន ឯកាធិភាព អ្នកផ្តត់ផ្តង់សេវាកម្មផ្តាច់មុខ ឬ លក្ខណ្ឌតម្រូវក្នុងការធ្វើតេស្តតម្រូវការសេដ្ឋកិច្ច

(ខ) ការកំណត់លើតម្លៃសរុបនៃប្រតិបត្តិការសេវាកម្ម ឬ ទ្រព្យសកម្មក្នុងទម្រង់ជាកូតាចំនួន ឬ លក្ខណ្ឌតម្រូវក្នុងការធ្វើតេស្តតម្រូវការសេដ្ឋកិច្ច

(គ) ការកំណត់លើចំនួនសរុបនៃការប្រតិបត្តិសេវាកម្ម ឬ លើបរិមាណសរុបនៃទិន្នផលសេវាកម្ម គិតជាឯកតាក្នុងទម្រង់ជាកូតា ឬ លក្ខណ្ឌតម្រូវក្នុងការធ្វើតេស្តតម្រូវការសេដ្ឋកិច្ច[៨]

(ឃ) ការកំណត់លើចំនួនសរុបនៃរូបវន្តបុគ្គល ដែលអាចត្រូវបានជួលមកធ្វើការនៅក្នុងវិស័យសេវាកម្មជាក់លាក់ណាមួយ ឬ ក៏អ្នកផ្តត់ផ្តង់សេវាកម្មអាចជួលមកធ្វើការបាន ជារូបវន្តបុគ្គលដែលចាំបាច់និងមានការពាក់ព័ន្ធផ្ទាល់ទៅនឹងការផ្តត់ផ្តង់សេវាកម្មណាមួយក្នុងទំរង់ជាបរិមាណ កូតា ឬ លក្ខខណ្ឌតម្រូវក្នុងការធ្វើតេស្តតម្រូវការសេដ្ឋកិច្ច

---

[៧] ក្នុងករណីភាគីមួយអនុវត្តនូវការសន្យាច្រកចូលទីផ្សារណាមួយ ដែលពាក់ព័ន្ធនឹងការផ្តត់ផ្តង់សេវាកម្មណាមួយ តាមរយៈប្រភេទនៃការផ្តត់ផ្តង់ ដូចបានលើកឡើងក្នុងកថាខណ្ឌ (ɪ)(i) នៃមាត្រា២ (និយមន័យ) នៃកិច្ចព្រមព្រៀងនេះ និងករណីបម្លាស់ទីមូលធនឆ្លងកាត់ព្រំដែនគឺជាផ្នែកដ៏ចម្បងមួយនៃសេវាកម្មផងដែរ ដែលភាគីនោះបានសន្យាដើម្បីអនុញ្ញាតចំពោះបម្លាស់ទីមូលធនបែបនេះ។ ក្នុងករណី ភាគីមួយអនុវត្តការសន្យាបើកច្រកចូលទីផ្សារដោយពាក់ព័ន្ធនឹងការផ្តត់ផ្តង់សេវាកម្មណាមួយតាមរយៈវិធីសាស្ត្រនៃការផ្តត់ផ្តង់ ដូចបានលើកឡើងក្នុងកថាខណ្ឌ (ɪ)(iii) នៃមាត្រា២ (និយមន័យ) នៃកិច្ចព្រមព្រៀងនេះ ភាគីនោះបានសន្យាដើម្បីអនុញ្ញាតចំពោះការផ្ទេរមូលធនទៅក្នុងដែនដីរបស់ខ្លួន។

[៨] កថាខណ្ឌទី ២(គ) នៃមាត្រានេះមិនគ្របដណ្តប់លើរាល់វិធានការទាំងឡាយណារបស់ភាគីណាមួយ ដែលដាក់កម្រិតចំពោះធាតុចូលសម្រាប់ការផ្តត់ផ្តង់សេវាកម្មឡើយ។

(ង) វិធានការទាំងឡាយណាដែលរឹតបន្តឹង ឬ តម្រូវឲ្យមាននីតិបុគ្គលជាក់លាក់ ឬ ក្រុមហ៊ុនចម្រុះទុនទើបអ្នកផ្តត់ផ្គង់សេវាកម្មអាចផ្តល់សេវាកម្មណាមួយបាន និង

(ច) ការកំណត់លើការរួមចំណែកនៃមូលធនបរទេស ក្នុងរូបភាពជាភាគរយអតិបរមាលើភាគទុនបរទេស ឬ តម្លៃសរុបនៃការវិនិយោគបរទេសជាលក្ខណៈបុគ្គល ឬ ជាលក្ខណៈរួម។

មាត្រា ១៨
ប្រព្រឹត្តិកម្មជាតិ

១. ចំពោះវិស័យនានាដែលបានចែងក្នុងតារាងសន្យារបស់ខ្លួន និងអាស្រ័យតាមលក្ខខណ្ឌនានា និងគុណវុឌ្ឍិដែលបានចែងក្នុងនោះ ភាគីនីមួយៗត្រូវផ្តល់នូវប្រព្រឹត្តិកម្មដែលមានភាពអនុគ្រោះដល់សេវាកម្ម និងអ្នកផ្តត់ផ្គង់សេវាកម្មនៃភាគីដទៃ ពាក់ព័ន្ធនឹងវិធានការនានាដែលជះឥទ្ធិពលលើការផ្តត់ផ្គង់សេវាកម្ម មិនឲ្យតិចជាងប្រព្រឹត្តិកម្មដែលខ្លួនបានផ្តល់ដល់សេវាកម្ម និងអ្នកផ្តត់ផ្គង់សេវាកម្មដូចគ្នារបស់ប្រទេសខ្លួនឡើយ ។[1]

២. ភាគីមួយអាចបំពេញតាមលក្ខខណ្ឌតម្រូវនៃកថាខណ្ឌ១ នៃមាត្រានេះបាន តាមរយៈការផ្តល់ប្រព្រឹត្តិកម្មដូចគ្នា ឬ ខុសគ្នា ដល់សេវាកម្ម និងអ្នកផ្តត់ផ្គង់សេវាកម្មនៃភាគីដទៃទៀត ដូចដែលបានផ្តល់ដល់សេវាកម្ម និងអ្នកផ្តត់ផ្គង់សេវាកម្មរបស់ខ្លួន។

៣. ប្រព្រឹត្តិកម្មដូចគ្នា ឬ ខុសគ្នា ត្រូវបានចាត់ទុកថាមានភាពអនុគ្រោះតិចជាង បើប្រព្រឹត្តិកម្មនោះបានកែប្រែលក្ខខណ្ឌប្រកួតប្រជែងដោយផ្តល់ផលប្រយោជន៍ដល់សេវាកម្ម ឬ អ្នកផ្តត់ផ្គង់សេវាកម្មនៃភាគីមួយ បើប្រៀបធៀបទៅនឹងសេវាកម្ម ឬ អ្នកផ្តត់ផ្គង់សេវាកម្មដូចគ្នា នៃភាគីមួយទៀត។

មាត្រា ១៩
ការសន្យាបន្ថែម

បណ្តាភាគីអាចចរចាលើការសន្យាទាក់ទងនឹងវិធានការនានា ដែលជះឥទ្ធិផលដល់ពាណិជ្ជកម្មសេវាកម្មដែលមិនមានក្នុងតារាងនៃការសន្យាដែលធ្វើឡើងក្រោមមាត្រា១៧ (ការបើកច្រកទីផ្សារ) និងមាត្រា១៨ (ប្រព្រឹត្តិកម្មជាតិ) រួមបញ្ចូលទាំងវិធានការនានាពាក់ព័ន្ធនឹងគុណវុឌ្ឍិ បទដ្ឋាន ឬ បញ្ហាអាជ្ញាប័ណ្ណ។ ការសន្យាទាំងនោះត្រូវតែចែងក្នុងតារាងសន្យារបស់ភាគី ។

មាត្រា ២០
តារាងនៃការសន្យាជាក់លាក់

[1] ការសន្យាតាមវិស័យដែលបានសន្មតក្នុងមាត្រានេះ មិនត្រូវបានបកស្រាយដើម្បីតម្រូវឲ្យភាគីណាមួយធ្វើសំណងទូទាត់ចំពោះគុណវិបត្តិផ្នែកប្រកួតប្រជែងបណ្តាលមកពីលក្ខណៈបរទេសនៃសេវាកម្មពាក់ព័ន្ធ ឬ អ្នកផ្តត់ផ្គង់ពាក់ព័ន្ធ ។

១. ភាគីនីមួយៗ ត្រូវកំណត់នៅក្នុងតារាងពីការសន្យាជាក់លាក់ពីការសន្យារបស់ខ្លួន ដែលមានចែងនៅក្រោមមាត្រា១៧ (ការបើកច្រកទីផ្សារ) មាត្រា១៨ (ប្រព្រឹត្តិកម្មជាតិ) និងមាត្រា១៩(ការសន្យាបន្ថែម) ។ ពាក់ព័ន្ធនឹងវិស័យនានា ដែលការសន្យាត្រូវបានធ្វើឡើង ភាគីនីមួយៗត្រូវបញ្ជាក់អំពី៖

(ក) បណ្តាវិស័យ ដែលការសន្យាត្រូវបានធ្វើឡើង

(ខ) លក្ខខណ្ឌ ការកំណត់ លើការបើកច្រកទីផ្សារ

(គ) លក្ខខណ្ឌ និងគុណវុឌ្ឍិលើប្រព្រឹត្តិកម្មជាតិ

(ឃ) ការអនុវត្តផ្សេងៗពាក់ព័ន្ធនឹង ការសន្យាបន្ថែម និង

(ង) រយៈពេលសម្រាប់អនុវត្តកិច្ចសន្យាទាំងនេះ។

២. វិធានការដែលមិនស្របនឹងមាត្រា១៧ (ការបើកទីផ្សារ) និងមាត្រា១៨ (ប្រព្រឹត្តិកម្មជាតិ) ត្រូវចែងក្នុងតារាងដែលពាក់ព័ន្ធនឹងមាត្រា១៧ (ការបើកទីផ្សារ)។ ក្នុងករណីនេះ ការចែងបែបនោះ គឺជាការផ្តល់លក្ខខណ្ឌ ឬ គុណវុឌ្ឍិ ដល់មាត្រា១៨ (ប្រព្រឹត្តិកម្មជាតិ) ។

៣. ក្នុងករណីការសន្យាត្រូវបានធ្វើឡើងពាក់ព័ន្ធនឹងបម្លាស់ទីរូបវន្តបុគ្គល ការសន្យានោះត្រូវរួមបញ្ចូលប្រភេទរូបវន្តបុគ្គលមួយ ឬ ច្រើន ដូចដែលមានចែងក្នុងឧបសម្ព័ន្ធស្តីពីបម្លាស់ទីរូបវន្តបុគ្គល យោងទៅលើកថាខណ្ឌ១ នៃមាត្រានេះ ។

៤. តារាងសន្យាជាក់លាក់របស់បណ្តាភាគីត្រូវភ្ជាប់ជាឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ និងក្លាយជាផ្នែកសួលនៃកិច្ចព្រមព្រៀងនេះ នៅពេលការចរចាត្រូវបានបញ្ចប់។

មាត្រា២១
ការអនុវត្ត និងការបន្តការសន្យា

១. ភាគីឥណ្ឌា ត្រូវបង្កើតតារាងនៃការសន្យាជាក់លាក់តែមួយក្រោមមាត្រា២០ (តារាងនៃការសន្យាជាក់លាក់) ហើយត្រូវអនុវត្តចំពោះប្រទេសព្រុយណេ កម្ពុជា ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា សឹង្ហបុរី ថៃ និងវៀតណាម និងត្រូវបង្កើតតារាងនៃការសន្យាជាក់លាក់ដាច់ដោយឡែកចំពោះប្រទេសឥណ្ឌូនេស៊ី និង ហ្វីលីពីន ។

២. ប្រទេសសមាជិកអាស៊ាននីមួយៗ ត្រូវបង្កើតតារាងនៃការសន្យាជាក់លាក់រៀងៗខ្លួនក្រោមមាត្រា ២០ (តារាងនៃការសន្យាជាក់លាក់) និងត្រូវអនុវត្តតារាងនេះចំពោះភាគីឥណ្ឌា និងសមាជិកអាស៊ានដទៃទៀត ។

មាត្រា ២២
ការកែប្រែតារាងនៃការសន្យា

១. ភាគីមួយអាចកែប្រែ ឬដកចេញនូវការសន្យាណាមួយនៅក្នុងតារាងពេលណាក៏បាន បន្ទាប់ពីរយៈពេលបីឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលការសន្យានោះបានចូលជាធរមាន ក្នុងករណីដែល៖

(ក) ភាគីនោះជូនដំណឹងដល់គណៈកម្មាធិការចម្រុះផ្នែកសេវាកម្ម អំពីចេតនារបស់ខ្លួនក្នុងការកែប្រែ ឬ ដកចេញនូវការសន្យាមិនតិចជាងបីខែ មុនកាលបរិច្ឆេទនៃការអនុវត្តចំពោះការកែប្រែ ឬ ការដកចេញនោះ និង

(ខ) ភាគីនោះត្រូវ ចរចាជាមួយភាគីដែលរងការប៉ះពាល់ ដើម្បីឯកភាពគ្នាអំពីសំណងទូទាត់។

២. ដើម្បីសម្រេចបាននូវសំណងទូទាត់មួយ បណ្តាភាគីត្រូវជានាថា កម្រិតទូទៅនៃការសន្យា ត្រូវមានភាពអនុគ្រោះចំពោះពាណិជ្ជកម្មមិនតិចជាងអ្វីដែលធ្លាប់បានផ្តល់ក្នុងតារាងសន្យា កាលពីមុនពេលចរចានេះឡើយ។

៣. សំណងទូទាត់ណាមួយ ដែលអនុលោមតាមមាត្រានេះ នឹងត្រូវបានផ្តល់ជូនដោយឈរលើមូលដ្ឋានមិនរើសអើងចំពោះគ្រប់ភាគីទាំងអស់។

៤. ប្រសិនបើភាគីពាក់ព័ន្ធមិនអាចសម្រេចបាននូវការព្រមព្រៀងគ្នាស្តីពីសំណងទូទាត់ណាមួយទេ បញ្ហានេះត្រូវដោះស្រាយក្រោមកិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយវិវាទអាស៊ាន-ឥណ្ឌា។ ភាគីដែលកែប្រែមិនត្រូវអនុវត្តការកែប្រែ ឬ ការដកចេញនូវការសន្យារបស់ខ្លួនឡើយ រហូតទាល់តែខ្លួនបានផ្តល់សំណងទូទាត់សមរម្យស្របតាមសេចក្តីសម្រេចរបស់អជ្ញាកណ្តាលរួចរាល់សិន។

៥. ប្រសិនបើភាគីកែប្រែ អនុវត្តគម្រោងកែប្រែ ឬ ដកចេញនូវការសន្យារបស់ខ្លួន ហើយមិនស្របតាមសេចក្តីសម្រេចរបស់អជ្ញាកណ្តាលទេនោះ ភាគីនានាដែលបានចូលរួមក្នុងការដោះស្រាយជម្លោះ អាចកែប្រែ ឬ ដកចេញនូវផលប្រយោជន៍នានាដែលសមមូល ដោយអនុលោមតាមសេចក្តីសម្រេចនោះ។ ទោះជាមានចែងក្នុងមាត្រា២១ (ការអនុវត្ត និងការបន្តការសន្យា) ក៏ដោយ ក៏ការកែប្រែ ឬ ការដកចេញបែបនេះអាចត្រូវបានអនុវត្តចំពោះតែភាគីកែប្រែប៉ុណ្ណោះ។

ផ្នែកទី ៤ ៖ បទប្បញ្ញត្តិផ្សេងៗ

មាត្រា ២៣

ទំនាក់ទំនងនឹងកិច្ចព្រមព្រៀងផ្សេងទៀត

១. ភាគីនីមួយៗអះអាងសាជាថ្មីនូវសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនជាមួយភាគីដទៃទៀតក្រោមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក និងកិច្ចព្រមព្រៀងផ្សេងៗដែលភាគីទាំងនេះ ជាសមាជិក។

២. កិច្ចព្រមព្រៀងនេះ ពុំត្រូវបកស្រាយ ដើម្បីប្រឆាំងនឹងសិទ្ធិ ឬកាតព្វកិច្ចណាមួយរបស់ភាគីណាមួយដែលនៅក្រោមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក និងកិច្ចព្រមព្រៀងផ្សេងៗទៀត ដែលភាគីទាំងនោះជាសមាជិកឡើយ។

៣. ក្នុងករណីដែលមានភាពមិនស្របគ្នារវាងកិច្ចព្រមព្រៀងនេះ និងកិច្ចព្រមព្រៀងផ្សេងទៀតដែលភាគីពីរ ឬ ច្រើនជាសមាជិក ភាគីទាំងនោះត្រូវពិគ្រោះយោបល់គ្នាមក្នុងគោលបំណងស្វែងរកដំណោះស្រាយសមស្របទៅវិញទៅមក។

៤. កិច្ចព្រមព្រៀងនេះ ពុំបានរារាំងសមាជិកអាស៊ាននីមួយៗ ពីការចូលជាសមាជិកក្នុងកិច្ចព្រមព្រៀងណាមួយជាមួយនឹងប្រទេសសមាជិកអាស៊ានមួយ ឬច្រើន និង/ឬ ជាមួយភាគីឥណ្ឌានោះទេ។

៥. កិច្ចព្រមព្រៀងនេះ មិនត្រូវយកទៅអនុវត្តលើកិច្ចព្រមព្រៀងណាមួយក្នុងចំណោមប្រទេសសមាជិកអាស៊ាន ឬ លើកិច្ចព្រមព្រៀងរវាងសមាជិកអាស៊ានណាមួយ និងឥណ្ឌា លើកលែងតែមានការឯកភាពពីបណ្តាភាគីនៃកិច្ចព្រមព្រៀងនោះ។

មាត្រា ២៤

ឧបសម្ព័ន្ធ និងលិខិតុបករណ៍គតិយុត្តិនាពេលអនាគត

១. ឧបសម្ព័ន្ធជាផ្នែកសួលមួយនៃកិច្ចព្រមព្រៀងនេះ

២. បណ្តាភាគីអាចអនុម័តលិខិតុបករណ៍គតិយុត្តិនាពេលអនាគត ដោយអនុលោមតាមបទប្បញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ រួមទាំងបទប្បញ្ញត្តិទាំងឡាយណាដែលបានស្នើដោយគណៈកម្មាធិការចម្រុះសេវាកម្ម ។ នៅពេលចូលជាធរមាន លិខិតុបករណ៍ទាំងនេះគឺជាផ្នែកសួលមួយនៃកិច្ចព្រមព្រៀងនេះ។

មាត្រា ២៥
មន្ត្រីសម្រាប់ទំនាក់ទំនង

១. ភាគីនីមួយៗត្រូវចាត់តាំងមន្ត្រីសម្រាប់ទំនាក់ទំនង ដើម្បីសម្រួលទំនាក់ទំនងរវាងបណ្តាភាគី លើរាល់បញ្ហាដែលត្រូវបានគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះ រួមបញ្ចូលទាំងការផ្តាស់ប្តូរព័ត៌មានទាក់ទងនឹងការអនុវត្ត និងការប្រតិបត្តិកិច្ចព្រមព្រៀងនេះ។

២. នៅពេលមានសំណើរបស់ភាគីណាមួយ មន្ត្រីសម្រាប់ទំនាក់ទំនងរបស់ភាគីដែលត្រូវបានស្នើត្រូវកំណត់ការិយាល័យ ឬ មន្ត្រីទទួលខុសត្រូវលើបញ្ហានេះ និងជួយសម្របសម្រួលដល់ទំនាក់ទំនងជាមួយភាគីស្នើសុំ។

មាត្រា ២៦
គណៈកម្មាធិការចម្រុះសេវាកម្ម

១. គណៈកម្មាធិការចម្រុះសេវាកម្ម ត្រូវបង្កើតឡើងក្រោមកិច្ចព្រមព្រៀងនេះ ក្នុងរយៈពេលមួយឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។

២. មុខងារនៃគណៈកម្មាធិការចម្រុះសេវាកម្មមានដូចជា៖

(ក) ពិនិត្យឡើងវិញនូវការអនុវត្ត និងការប្រតិបត្តិកិច្ចព្រមព្រៀងនេះ

(ខ) ផ្ញើរបាយការណ៍ទៅបណ្តាភាគីពីការអនុវត្ត និងការប្រតិបត្តិកិច្ចព្រមព្រៀងនេះ

(គ) ពិចារណា និងផ្តល់អនុសាសន៍ដល់បណ្តាភាគី ពីវិសោធនកម្មទាំងឡាយលើកិច្ចព្រមព្រៀងនេះ

(ឃ) ត្រួតពិនិត្យ និងសម្របសម្រួលកិច្ចការរបស់អនុគណៈកម្មាធិការទាំងអស់ ដែលបានបង្កើតឡើងក្រោមកិច្ចព្រមព្រៀងនេះ និង

(ង) អនុវត្តមុខងារផ្សេងៗទៀត តាមការឯកភាពពីភាគីទាំងអស់។

៣. គណៈកម្មាធិការចម្រុះសេវាកម្ម៖

(ក) ត្រូវមានសមាសភាពតំណាងពីភាគីនីមួយៗ និង

(ខ) អាចបង្កើតអនុគណៈកម្មាធិការ និងប្រគល់ទំនួលខុសត្រូវដល់អនុគណៈកម្មាធិការនោះ។

មាត្រា ២៧
ការពិនិត្យមើលឡើងវិញ

គណៈកម្មាធិការចម្រុះសេវាកម្ម ត្រូវជួបប្រជុំគ្នារយៈពេលមួយឆ្នាំបន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ដើម្បីពិនិត្យមើលឡើងវិញនូវការអនុវត្ត និងការប្រតិបត្តិកិច្ចព្រមព្រៀងនេះ ឬដូចដែលបានឯកភាពគ្នាទៅវិញទៅមក។ បន្ទាប់ពីនោះមក រៀងរាល់ពីរឆ្នាំម្តង ឬ ក្នុងរយៈពេលសមស្របមួយ គណៈកម្មាធិការចម្រុះសេវាកម្មត្រូវពិនិត្យឡើងវិញលើកិច្ចព្រមព្រៀងនេះ ក្នុងគោលបំណងធ្វើសេរីភាវូបនីយកម្មជាបន្តបន្ទាប់លើពាណិជ្ជកម្មសេវាកម្ម ក៏ដូចជាការបង្កើតវិន័យ និងការចចារលើកញ្ចប់សន្យាបន្តបន្ទាប់ ដូចដែលបានឯកភាពគ្នា ដើម្បីសម្រួលដល់ការលុបបំបាត់ការរើសអើងដែលនៅមានរវាងបណ្តាភាគីទាក់ទងពាណិជ្ជកម្មសេវាកម្មនៅក្រោមកិច្ចព្រមព្រៀងនេះ រួមទាំងឧបសម្ព័ន្ធស្តីពីបម្លាស់ទីរូបវន្តបុគ្គលផងដែរ។

មាត្រា ២៨
បទឃ្ញត្តិផ្សេងៗ

១. ឧបសម្ព័ន្ធនានារបស់ GATS ដូចជា ឧបសម្ព័ន្ធស្តីពីបម្លាស់ទីរូបវន្តបុគ្គលដែលផ្តត់ផ្តង់សេវាកម្ម ឧបសម្ព័ន្ធស្តីពីសេវាកម្មដឹកជញ្ជូនផ្លូវអាកាស ឧបសម្ព័ន្ធស្តីពីសេវាកម្មហិរញ្ញវត្ថុ និងឧបសម្ព័ន្ធស្តីពីទូរគមនាគមន៍ ត្រូវអនុវត្តលើកិច្ចព្រមព្រៀងនេះ ទោះជាមានការកែប្រែក៏ដោយ (mutatis mutandis)។

២. កិច្ចព្រមព្រៀងនេះត្រូវរួមបញ្ចូល (ក) ឧបសម្ព័ន្ធនានាដែលរួមបញ្ចូលនូវឧបសម្ព័ន្ធស្តីពីបម្លាស់ទីរូបវន្តបុគ្គលដែលបានឯកភាពគ្នាក្រោមកិច្ចព្រមព្រៀងនេះ ព្រមទាំងមាតិកានានាដែលជាផ្នែកស្នូលមួយនៃកិច្ចព្រមព្រៀងនេះ និង (ខ) វាល់លិខិតុបករណ៍គតិយុត្តិនាពេលអនាគតដែលត្រូវបានឯកភាព ដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ។

